រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ឯកសារបច្ចេកទេស

# ស្តីពី

# ដីកា

# ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

លេខាធិការដ្ឋាន គ.ជ.អ.ប

ខែវិច្ឆិកា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ: ០៧៥ [illegible] /គ.ជ.អ.ប

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់ឯកសារបច្ចេកទេស
## ស្តីពីដីការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## គណៈកម្មាធិការជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ មាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួននៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៨៦/អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវឯកសារបច្ចេកទេសស្ដីពី "ដីការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" ។

**ប្រការ ២.-**

ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល នាយកទីចាត់ការ ប្រធានការិយាល័យ និងមន្ត្រីរាជការទាំងអស់នៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាត្រូវរៀបចំតាក់តែងដីកា កែប្រែដីកា និងលុបចោលដីកា ដោយអនុវត្តតាមបែបបទ នីតិវិធីដូចបានកំណត់ក្នុងឯកសារបច្ចេកទេសនេះ តាមតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

**ប្រការ ៣.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មានភារកិច្ចផ្ដល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំតាក់តែងដីកា កែប្រែដីកា និងលុបចោលដីការបស់ខ្លួន ព្រមទាំងអនុវត្តដីកាប្រកបដោយប្រសិទ្ធភាព ។

**ប្រការ ៤.-**

សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី..១៥.. ខែ[illegible]... ឆ្នាំ២០១៥*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**សម្ដេចក្រឡាហោម ស ខេង**

**__ចម្លងជូន__**

- ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប (ដើម្បីជូនជ្រាប)
- ដូចប្រការ២ និង ប្រការ៣ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ ។

# អារម្ភកថា

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន ផ្តល់ឱ្យក្រុមប្រឹក្សានូវសិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការដាក់ចេញដីកា និងសិទ្ធិអំណាចខាងប្រតិបត្តិ តាមរយៈការដាក់ចេញនូវសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ខ្លួនតាមការចាំបាច់។

ដើម្បីធានាការប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំ និងដាក់ចេញនូវដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ២៨៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធី សម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។ ចំពោះការរៀបចំ និងដាក់ចេញនូវដីកាដែលមានលក្ខណៈជាបុគ្គល រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ៤៩៧ ចុះថ្ងៃ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

ផ្អែកលើអនុក្រឹត្យនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំឯកសារបច្ចេកទេសស្តីពីដីកាសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដោយមានការសហការ និងគាំទ្រពីកម្មវិធីសហភាពអឺរ៉ុបដើម្បីលើកកម្ពស់ការបំពេញការងារគណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ (EU-SPACE) ដើម្បីជាជំនួយស្មារតីដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំតាក់

តែងនូវដីការបស់ខ្លួនដែលមានលក្ខណៈជាបទបញ្ជាទូទៅ និងដែលមានលក្ខណៈជាបុគ្គល។

ឯកសារបច្ចេកទេសនេះ ពុំមែនជាក្របខ័ណ្ឌគតិយុត្តដែលតម្រូវឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមទាំងស្រុងនោះទេ។ ក្នុងន័យនេះ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចពិចារណាប្រើប្រាស់ឯកសារបច្ចេកទេសនេះប្រកបដោយភាពបត់បែន ផ្អែកតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ឯកសារបច្ចេកទេសនេះ មិនគ្របដណ្តប់លើដំណើរការរៀបចំតាក់តែងដីការបស់រដ្ឋបាលឃុំ សង្កាត់ឡើយ។ លេខាធិការដ្ឋាន គ.ជ.អ.ប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរួមចំណែកពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធនានាដែលបានផ្តល់មតិយោបល់ និងអនុសាសន៍នានាសម្រាប់រៀបចំឯកសារបច្ចេកទេសនេះ។ ទន្ទឹមនឹងនេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះយោបល់ស្ថាបនា ដើម្បីកែលម្អឯកសារបច្ចេកទេសនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

# មាតិកា


អារម្ភកថា.......................................................................................

សេចក្តីផ្តើម...................................................................................ii

**ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ**

១.១. ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត..........................................១

១.២. និយមន័យ.......................................................................................៩

**ផ្នែកទី២ ៖ ការរៀបចំតាក់តែងដីកា**

២.១. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការដាក់ចេញដីកា.............................១២

២.២. គោលការណ៍នៃការដាក់ចេញដីកា.....................................................១៤

២.៣. ដំណើរការរៀបចំ និងការអនុម័តដីកា...............................................១៥

២.៣.១. ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ.............................១៥

២.៣.២. ដីកាដែលមានលក្ខណៈឯកត្តភូត.......................................៣៧

២.៤. ការពិនិត្យនីត្យានុកូលភាពដីកា.........................................................៤១

**ផ្នែកទី៣ ៖ ការអនុវត្ត ការកែប្រែ និងការលុបចោលដីកា**

៣.១. ការអនុវត្តដីកា.................................................................................៤៤

៣.២. ការកែប្រែ និងការលុបចោលដីកា.....................................................៤៦

៣.៣. ការដាក់ពិន័យ..................................................................................៤៧

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១ ៖ អនុក្រឹត្យលេខ២៨៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤.....៤៨

ឧបសម្ព័ន្ធទី២ ៖ ទម្រង់ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ.............៥៨

ឧបសម្ព័ន្ធទី៣ ៖ ទម្រង់ដីកាដែលមានលក្ខណៈឯកត្តភូត......................៦០

# សេចក្តីផ្តើម

ឯកសារបច្ចេកទេសស្តីពីដីកាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង ធានាឱ្យមានការឯកភាព និងបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំតាក់តែងដីការបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ឯកសារបច្ចេកទេសនេះត្រូវបានរៀបចំផ្អែកលើក្របខ័ណ្ឌច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ ខ្លឹមសារលម្អិតនៃឯកសារបច្ចេកទេសនេះបានឆ្លុះបញ្ចាំងនូវដំណើរការ និងនីតិវិធីនានានៃការផ្តួចផ្តើមគំនិត និងការរៀបចំតាក់តែងដីការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានការចូលរួមពិគ្រោះយោបល់ពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ពាក់ព័ន្ធ សង្គមស៊ីវិល និងផ្នែកឯកជនស្របតាមតម្រូវការ និងសភាពការណ៍ជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

ដើម្បីជួយឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាចមានមូលដ្ឋានក្នុងការរៀបចំ និងដាក់ឱ្យអនុវត្តនូវដីការបស់ខ្លួន ឯកសារបច្ចេកទេសនេះ នឹងបរិយាយអំពីខ្លឹមសារសំខាន់ៗដូចខាងក្រោម ៖

- **ផ្នែកទី ១ ៖ ទិដ្ឋភាពទូទៅ** ដែលពិពណ៌នាអំពីក្របខ័ណ្ឌច្បាប់ និយមន័យ និងចរិតលក្ខណៈសំខាន់ៗនៃដីកា និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការរៀបចំដីកា។
- **ផ្នែកទី ២ ៖ ការរៀបចំតាក់តែងដីកា** ពិពណ៌នាអំពីលក្ខខណ្ឌចាំបាច់ក្នុងការដាក់ចេញដីកា ដំណើរការនៃការផ្តួចផ្តើមគំនិតក្នុងការរៀប

ចំដីកា ដំណើរការក្នុងការរៀបចំដីកា ការអនុម័តដីកា ការពិនិត្យនីត្យានុកូលភាពរបស់ដីកា និងការផ្សព្វផ្សាយដីកា ។

- **ផ្នែកទី៣ ៖ ការអនុវត្ត ការកែប្រែ និងការលុបចោលដីកា** ពិពណ៌នាអំពីដំណើរការនៃការអនុវត្ត ការកែប្រែ ការលប់ចោល និងការដាក់ពិន័យចំពោះការបំពានដីកា ។

# ផ្នែកទី១
# ទិដ្ឋភាពទូទៅ

# ផ្នែកទី១
# ទិដ្ឋភាពទូទៅ

ការរៀបចំ ការកែប្រែ និងលុបចោលដីការបស់ក្រុមប្រឹក្សាជាដំណើរការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា នីតិវិធី ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ។

ផ្នែកទី១ ទិដ្ឋភាពទូទៅ ពិពណ៌នាអំពីក្របខ័ណ្ឌច្បាប់ ដែលផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញដីកា និយមន័យ និងចរិតលក្ខណៈសំខាន់ៗនៃដីកា និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការរៀបចំដីកាផងដែរ ។

## ១.១. ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបានផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ រួមមាន ៖

### ក). ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ដូចខាងក្រោម ៖

- ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិតាមរយៈការដាក់ចេញនូវដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈការដាក់ចេញនូវសេចក្តីសម្រេចក្នុងកិច្ចប្រជុំរបស់ខ្លួន ។
- រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬដីកាតាមការចាំបាច់ទាក់ទិនទៅនឹង ៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្រប តាមការកំណត់នៃច្បាប់
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ។

- ក្រុមប្រឹក្សាត្រូវធានាថា ដីកា និងសេចក្ដីសម្រេចរបស់ខ្លួនត្រូវបានអនុវត្ត។

## ខ). អនុក្រឹត្យ

ដើម្បីអនុវត្តបញ្ញត្តិនានាដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងដាក់ឱ្យអនុវត្តនូវអនុក្រឹត្យនានាដូចខាងក្រោម ៖

- អនុក្រឹត្យលេខ២១៥ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ។
- អនុក្រឹត្យលេខ២១៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- អនុក្រឹត្យលេខ ២៨៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

### ខ.១. អនុក្រឹត្យលេខ ២១៥ និង ២១៦

អនុក្រឹត្យលេខ២១៥ និងលេខ២១៦ បានចែងអំពីការអនុវត្តសិទ្ធិអំណាចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខណ្ឌ (២១៥) និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក (២១៦) ក្នុងការចេញសេចក្តីសម្រេច និងការដាក់ចេញនូវដីកាដូចខាងក្រោម ៖

- រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើដីកា ឬសេចក្តីសម្រេចតាមការចាំបាច់ទាក់ទិនទៅនឹង ៖
  - ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមការកំណត់នៃច្បាប់
  - ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
  - ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
  - ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា
  - ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
  - បញ្ហាហិរញ្ញវត្ថុផ្សេងរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
  - ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
  - ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សា ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សា
  - ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានា ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

• ក្រៅពីការសម្រេចខាងលើ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើសេចក្តីសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ និង ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងទៀត រួមមាន ៖
  - ការកោះអញ្ជើញអភិបាល ឬគណៈអភិបាល ឬបុគ្គលិកដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ឬហេតុការណ៍ណាមួយដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬការដោះស្រាយបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធក្នុងរដ្ឋបាលរបស់ខ្លួន
  - ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណា ដែលក្រុមប្រឹក្សាយល់ថាមានសារសំខាន់ដល់ប្រជាពលរដ្ឋ និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះ។
  - ការពិនិត្យ ការស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃក្នុងករណីមានការរំលោភអំណាច
  - ការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង ឬគណៈអភិបាល ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សា

- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋាន
- ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំដែលរៀបចំដោយគណៈអភិបាល
- បញ្ហាផ្សេងៗទៀត ដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សា ឬគណៈអភិបាលយល់ឃើញថាចាំបាច់។

- ក្រុមប្រឹក្សាត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធី ដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- ក្នុងករណីកិច្ចការណាមួយ ដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ មិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាត្រូវចាត់ឱ្យអភិបាលធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនោះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទ នីតិវិធីដើម្បីដោះស្រាយកិច្ចការទាំងនេះ។

- ក្នុងករណីកិច្ចការណាមួយដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយក្រុមប្រឹក្សាមិនអាចអនុវត្តបាន ក្រុមប្រឹក្សាត្រូវចាត់ឱ្យគណៈអភិបាលធ្វើសំណើមកក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្អែកតាមយន្តការ គ.ជ.អ.ប ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។
- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាបានសម្រេចរួចហើយ គណៈអភិបាលត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។
- គណៈអភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន រៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា។
- ក្រុមប្រឹក្សាត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាល ដើម្បីធានាថា គណៈអភិបាលអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សា។
- ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្តត្រូវស្ថិតនៅក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រសួងមហាផ្ទៃ។

- ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌត្រូវស្ថិតនៅក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រុមប្រឹក្សារាជធានី។
- ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុកត្រូវស្ថិតនៅក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រុមប្រឹក្សាខេត្ត។

**ខ.២. អនុក្រឹត្យលេខ ២៨៦**

អនុក្រឹត្យលេខ ២៨៦ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាខណ្ឌបានកំណត់អំពីបញ្ញត្តិទូទៅ គោលការណ៍សំខាន់ៗ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការចេញដីកា នីតិវិធីនៃការរៀបចំ ការអនុម័ត ការកែប្រែ ការលុបចោល ការអនុវត្ត និងការពិនិត្យនីត្យានុកូលភាពនៃដីកា។ ខ្លឹមសារលម្អិតនៃអនុក្រឹត្យនេះមាននៅក្នុងឧបសម្ព័ន្ធទី១។

**ខ.៣. អនុក្រឹត្យលេខ ៤៩៧**

អនុក្រឹត្យលេខ ៤៩៧ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពី ការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ចរបស់មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ កំណត់អំពីបញ្ញត្តិទូទៅ គោលការណ៍សំខាន់ៗ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការចេញដីកា នីតិវិធីនៃការរៀបចំ ការអនុម័ត ការកែប្រែ ការលុបចោល ការអនុវត្ត និងការពិនិត្យនីត្យានុកូលភាពនៃដីកា។

## ១.២. និយមន័យ

**ដីកា** គឺជាប្រភេទលិខិតបទដ្ឋានគតិយុត្តដែលដាក់ចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដីកាមានពីរប្រភេទ គឺដីកាមានលក្ខណៈជាបទបញ្ជាទូទៅ និងដីកាមានលក្ខណៈជាឯកត្តភូត ។ ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា។ ដីកាដែលមានលក្ខណៈជាឯកត្តភូត ត្រូវចុះហត្ថលេខាដោយអភិបាល តាមការសម្រេចរបស់ក្រុមប្រឹក្សា។ ដីកាទាំងមូល ឬផ្នែកខ្លះនៃដីកាអស់សុពលភាពនៅពេលដែលមានដីកាថ្មីមកជំនួស ឬច្បាប់ ឬលិខិតបទដ្ឋានដែលមានឋានានុក្រមខ្ពស់ជាងបាននិរាករណ៍នូវដីកា ឬបញ្ញត្តិណាមួយនៃដីកានោះ។

វាក្យស័ព្ទដែលប្រើក្នុងឯកសារបច្ចេកទេសនេះ មានដូចខាងក្រោម ៖

- **ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ** គឺជាការណែនាំការអនុវត្ត ឬបញ្ជាក់បន្ថែមខ្លឹមសាររបស់ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស និងជាការណែនាំការអនុវត្តកិច្ចការ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ ត្រូវអនុម័តដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា។
- **ដីកាដែលមានលក្ខណៈជាឯកត្តភូត** គឺជាដីកាដែលទាក់ទង ឬសំដៅចំឈ្មោះបុគ្គល។ ដីកាដែលមានលក្ខណៈជាឯកត្តភូតត្រូវអនុម័តដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយអភិបាល តាមការសម្រេចរបស់ក្រុមប្រឹក្សា។
- **ដីកាដើម** សំដៅដល់ដីកាដំបូងដែលបានរៀបចំ និងអនុម័តដោយ

ក្រុមប្រឹក្សា។

- **ដែនសមត្ថកិច្ច** គឺជាតំបន់ ជាមុខងារ និងជាភារកិច្ច ដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា។
- **ប្រតិសកម្ម** សំដៅដល់អនុភាពអនុវត្តត្រឡប់ក្រោយចំពោះស្ថានភាព ឬករណីទាំងឡាយណាដែលបានកើតមានឡើងមុនដីកាចូលជាធរមាន។
- **ការពិនិត្យនីត្យានុកូលភាព** គឺជាការត្រួតពិនិត្យ ដើម្បីធានាថាដីការបស់ក្រុមប្រឹក្សាត្រូវបានរៀបចំឡើងស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។
- **នគរបាលយុត្តិធម៌** សំដៅដល់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់កំណត់ដោយឡែក ប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។ នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

**ឧទាហរណ៍ ៖**

- ក្រុមប្រឹក្សាក្រុងស្ទឹងសែន ចេញដីកាមួយស្តីពីការហាមឃាត់ការបង្កសំឡេងរំខាន។ ដីកានេះចែងថា ការបន្លឺសំឡេងខ្លាំងៗ ត្រូវបានហាមឃាត់ចាប់ពីម៉ោង១០យប់ដល់ម៉ោង០៥

ព្រឹក។ ដីកានេះត្រូវអនុវត្តចំពោះប្រជាពលរដ្ឋគ្រប់រូបនៅក្នុងក្រុងស្ទឹងសែន។

- ក្រុមប្រឹក្សាស្រុកបរិបូរណ៍ ចេញដីកាមួយអំពីការកំណត់ការសង់រោងការ ឬរោងបុណ្យនៅតាមដងផ្លូវសាធារណៈ។ ក្នុងចំណោមចំណុចផ្សេងៗ ដីកានេះលើកឡើងថា ការសង់រោងបែបនេះអាចអនុញ្ញាតឱ្យសង់បានត្រឹមតែមួយភាគបីលើផ្លូវប៉ុណ្ណោះ។ ការសង់រោងនេះ ត្រូវមានការអនុញ្ញាតពីរដ្ឋបាលស្រុក។ ដីកានេះ មានសុពលភាពតែចំពោះស្រុកបរិបូរណ៍តែប៉ុណ្ណោះ។
- ក្រុមប្រឹក្សាក្រុង ដាក់ចេញដីកាស្ដីពីវិធានការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ដោយចែងថា "បុគ្គលដែលបោះចោលសំរាមសំណល់រឹងនៅលើទីសាធារណៈ តាមដងផ្លូវ ទីវាលដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលក្រុងហាមឃាត់ការបោះចោលសំរាមសំណល់រឹង នឹងត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្មតាមការកំណត់..."។

# ផ្នែកទី ២
# ការរៀបចំតាក់តែងដីកា

# ផ្នែកទី ២
# ការរៀបចំតាក់តែងដីកា

## ២.១. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការចេញដីកា

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការដាក់ចេញដីកា ដើម្បីកំណត់ ដើម្បីហាមឃាត់ ឬដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬលើកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនធានរបស់ខ្លួន។ ក្រៅពីនេះ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏អាចកែប្រែ ឬលុបចោលដីការបស់ខ្លួនផងដែរ។

ដីកាដែលក្រុមប្រឹក្សាដាក់ចេញ ត្រូវស្ថិតក្នុងវិសាលភាពនៃ ៖

- តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា
  ឧទាហរណ៍៖ ក្រុមប្រឹក្សាស្រុកចេញដីកាស្តីពីការថែទាំផ្លូវលំក្នុងស្រុក។
- មុខងារ និងឬធនធានដែលប្រគល់ទៅឱ្យក្រុមប្រឹក្សា ៖ នៅពេលដែលមុខងារ និងធនធាននានាត្រូវបានផ្ទេរពីក្រសួង ស្ថាប័ននៅថ្នាក់ជាតិទៅឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ ក្រុមប្រឹក្សានោះអាចចេញដីកា ដើម្បីអនុវត្តមុខងារដែលបានផ្ទេរឱ្យ។

  ឧទាហរណ៍ ៖ ក្នុងករណីក្រុមប្រឹក្សាស្រុកមួយទទួលបានមុខងារគ្រប់គ្រងបឹងធម្មជាតិនៅក្នុងស្រុក ក្រុមប្រឹក្សាស្រុកនោះអាចចេញដីកាស្តីពីការគ្រប់គ្រង និងប្រើប្រាស់បឹងធម្មជាតិនោះ ដូចជា ការ

ហាមឃាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និង ឬការហាមឃាត់ការប្រើប្រាស់ថ្នាំគីមីកសិកម្មនៅជុំវិញបឹង ជាដើម ។

- មុខងារ និងឬធនធាន ដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ៖ ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះមិនកំណត់ដោយផ្នែកខ្លះ ឬទាំងស្រុងនូវសិទ្ធិក្នុងការអនុម័តដីកា ក្រុមប្រឹក្សាអាចចេញដីកាពាក់ព័ន្ធនឹងការអនុវត្តមុខងារនោះ ។ ឧទាហរណ៍៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើប្រតិភូកម្មមុខងារក្នុងការគ្រប់គ្រងទីសត្តឃាតឱ្យក្រុមប្រឹក្សាស្រុក ។ ក្រុមប្រឹក្សាស្រុកនោះ អាចចេញដីកាស្ដីពីការកំណត់ទីសត្តឃាតក្នុងស្រុករបស់ខ្លួន ។
- កិច្ចការណាមួយដែលច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដែលតម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា ។ ឧទាហរណ៍៖ ក្រុមប្រឹក្សាចេញដីកាអំពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

ដីការបស់ក្រុមប្រឹក្សាក៏អាចដាក់បញ្ចូលនូវបទបញ្ញត្តិ ពាក់ព័ន្ធនឹងការពិន័យជាប្រាក់ ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណីផ្សេងៗទៀតចំពោះការបំពានលើបទប្បញ្ញត្តិមួយ ឬច្រើនដែលមានចែងនៅក្នុងដីកា ។ តាមន័យនេះ ដីការបស់ក្រុមប្រឹក្សាអាចកំណត់ពីចំនួនប្រាក់ពិន័យក្នុងការមិនអនុវត្តតាមការកំណត់ក្នុងដីកា ហើយប្រសិនបើកំហុស ឬ បទល្មើសនោះ មានស្ថានទម្ងន់ទោសពាក់ព័ន្ធនឹងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ជនល្មើសនោះ នឹងត្រូវទទួលទោសព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីបន្ថែមទៀត ។

បែបបទ និងនីតិវិធីនៃការរៀបចំបទប្បញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ដោយដីការបស់ក្រុមប្រឹក្សា និងកម្រិតនៃប្រាក់ពិន័យនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដូច្នេះ ក្នុងករណីក្រុមប្រឹក្សាសម្រេចដាក់ពិន័យជាប្រាក់ក្នុងបទប្បបញ្ញត្តិនៃដីការបស់ខ្លួន ក្រុមប្រឹក្សានោះត្រូវផ្អែកទៅលើកម្រិតនៃប្រាក់ពិន័យដែលបានកំណត់ក្នុងអនុក្រឹត្យជាធរមាន។ ក្នុងករណីដែលមិនមានអនុក្រឹត្យដែលកំណត់ពីកម្រិតនៃប្រាក់ពិន័យក្រុមប្រឹក្សា ត្រូវធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ២.២. គោលការណ៍នៃការចេញដីកា

ក្នុងការរៀបចំ និងដាក់ចេញដីការបស់ខ្លួន ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវពិចារណា និងអនុវត្តទៅតាមគោលការណ៍នានា ដូចខាងក្រោម ៖

- ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅត្រូវអនុម័តដោយក្រុមប្រឹក្សា និងត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា
- ដីកាដែលមានលក្ខណៈជាឯកត្តភូតត្រូវអនុម័តដោយក្រុមប្រឹក្សា និងត្រូវចុះហត្ថលេខាដោយអភិបាល
- ដីកាដែលថែងផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដីកានោះនឹងមិនមានសុពលភាពបានឡើយ

- ដីកាណាមួយ ដែលធ្វើឡើងដោយមានការរើសអើងក្នុងរូបភាពណាមួយ ក្នុងន័យអវិជ្ជមាន ឬអនុវត្តចំពោះបុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ជំនឿ និន្នាការនយោបាយ ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬ ជាតិកំណើត ឬ អសមត្ថភាពខាងស្មារតី ឬ ខាងកាយសម្បទា ដីកានោះនឹងមិនមានសុពលភាពបានឡើយ
- ក្រុមប្រឹក្សា ត្រូវធានាឱ្យមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំដីកា លើកលែងតែក្នុងករណីចាំបាច់ ដែលតម្រូវឱ្យក្រុមប្រឹក្សាត្រូវដាក់ចេញនូវដីកាដើម្បីដោះស្រាយ ឬ ចាត់វិធានការបន្ទាន់ណាមួយ
- ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលដីកានោះត្រូវបានចុះហត្ថលេខា ឬអាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគតសម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬផ្នែកខ្លះនៃដីកា
- ដីកាមិនអាចមានអនុភាពប្រតិសកម្មបានឡើយ
- ការរៀបចំ ការកែប្រែ ឬការលុបចោលដីកា តម្រូវឱ្យមាននីតិវិធីច្បាស់លាស់ដូចកំណត់ក្នុងអនុក្រឹត្យលេខ២៨៦។

## ២.៣. ដំណើរការនៃការរៀបចំ និងការអនុម័តដីកា

### ២.៣.១. ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ

ដំណើរការសំខាន់៧នៃការរៀបចំដីកា ដែលមានលក្ខណៈជាបទបញ្ជាទូទៅរួមមាន ៖

- ការកំណត់អំពីតម្រូវការនៃការដាក់ចេញដីកា
- ការរៀបចំសេចក្តីព្រាងដីកា
- ការពិគ្រោះយោបល់ និងការបិទផ្សាយសេចក្តីព្រាងដីកា និង
- ការពិនិត្យ និងការអនុម័តដីកា។

## ២.៣.១.១. ការកំណត់អំពីតម្រូវការនៃការដាក់ចេញដីកា

តម្រូវការនៃការដាក់ចេញដីកា ត្រូវបានកំណត់ដោយផ្អែកតាមតម្រូវការនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងឬតាមតម្រូវការនៅមូលដ្ឋាន។

### ក). ការផ្តួចផ្តើមអំពីតម្រូវការដីកា

ការផ្តួចផ្តើមអំពីតម្រូវការនៃការដាក់ចេញដីកា ដោយផ្អែកតាមតម្រូវការនៅមូលដ្ឋាន អាចស្នើឡើងដោយ ៖

- ប្រធានក្រុមប្រឹក្សា ឬ
- សមាជិកក្រុមប្រឹក្សាមួយភាគបី(១/៣)នៃសមាជិកក្រុមប្រឹក្សាទាំងមូល ឬ
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ឬ
- អភិបាល ឬ គណៈអភិបាល ឬ
- សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចនីមួយៗ ឬ
- តំណាងគ្រួសារចំនួនមួយភាគដប់(១/១០)នៃចំនួនគ្រួសារសរុបដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

### ខ). ការពិនិត្យ និងសម្រេចអំពីតម្រូវការដីកា

ដោយផ្អែកតាមសំណើដាក់ចេញដីកាខាងលើ ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងអនុម័តលើសំណើនេះ។ ក្នុងការពិនិត្យលើសំណើអំពីតម្រូវការដីកាក្រុមប្រឹក្សាគួរពិចារណាចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- តើបញ្ហាដែលលើកឡើងនៅក្នុងសំណើនៃការដាក់ចេញដីកាស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាសាមីដែរឬទេ?
- តើតម្រូវការនៃការរៀបចំដីកាស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាសាមីដែរឬទេ?
- តើវិសាលភាពនៃបញ្ហាដែលកំពុងជួបប្រទះ គួរត្រូវដោះស្រាយតាមរយៈការដាក់ចេញដីកា ឬសេចក្តីសម្រេច ឬគួរមានចំណាត់ការបែបណា?
- តើដីកានោះឆ្លើយតបទៅនឹងបំណងប្រាថ្នា និងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដែរឬទេ? ... ។ល។

## ២.៣.១.២. ការរៀបចំសេចក្តីព្រាងដីកា

### ក. អ្នកទទួលខុសត្រូវក្នុងការរៀបចំសេចក្តីព្រាងដីកា

ក្នុងការរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សាអាចប្រគល់ភារកិច្ចឱ្យ ៖

- សមាជិកក្រុមប្រឹក្សា ឬ
- គណៈអភិបាល ឬ
- គណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សាដែលមានស្រាប់ ឬ

- អង្គភាពណាមួយរបស់ក្រុមប្រឹក្សា ។

មុនសម្រេចប្រគល់ភារកិច្ចខាងលើឱ្យអ្នកទទួលបន្ទុកណាមួយ ក្រុមប្រឹក្សាគួរពិចារណាចំណុចមួយចំនួនដូចខាងក្រោម ៖

- តើគោលបំណងរបស់ដីកាចង់ដោះស្រាយបញ្ហាអ្វី?
- តើជំនាញអ្វីខ្លះដែលចាំបាច់ត្រូវមាន ដើម្បីរៀបចំតាក់តែងដីកា?
- តើគួរមានមន្ទីរ ការិយាល័យជំនាញ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាខ្លះត្រូវចូលរួម?

**ឧទាហរណ៍ ៖**

- ក្រុមប្រឹក្សាក្រុងមានផែនការដាក់ឱ្យអនុវត្តនូវការគ្រប់គ្រងចំណតយានយន្តនៅទីប្រជុំជនក្នុងក្រុង ។ ក្នុងការរៀបចំសេចក្តីព្រាងដីកាពីការគ្រប់គ្រងចំណតយានយន្តក្នុងក្រុងនេះ ក្រុមប្រឹក្សាអាចស្នើឱ្យគណៈអភិបាលរៀបចំដីកានេះបាន ។
- ដោយមើលឃើញអំពីបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការបោះចោល និងការគ្រប់គ្រងសំរាម ក្រុមប្រឹក្សាក្រុងសម្រេចដាក់ចេញដីកាមួយស្តីពីការគ្រប់គ្រងសំណល់រឹងក្នុងក្រុង ។ ក្នុងការរៀបចំសេចក្តីព្រាងដីកានេះ ក្រុមប្រឹក្សាបានសម្រេចបង្កើតក្រុមការងារមួយ ។ សមាសភាពក្នុងក្រុមការងារនេះ រួមមានអភិបាល នាយករដ្ឋបាល និងអ្នកជំនាញមកពីការិយាល័យបរិស្ថាន ការិយាល័យសាធារណការ និងដឹកជញ្ជូន ព្រមទាំងចៅសង្កាត់ទាំងអស់ក្នុងក្រុង ។

**កំណត់សម្គាល់ ៖**

- ក្នុងករណីតម្រូវឱ្យមានការបង្កើតក្រុមការងារដើម្បីរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សាត្រូវចេញសេចក្តីសម្រេចបង្កើតក្រុមការងារនោះ។
- ការតែងតាំង ឬការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយ ក្រុមប្រឹក្សាត្រូវធានាថាមានតំណាងស្ត្រីសមស្របនៅក្នុងសមាសភាពក្រុមនេះ។

## ២. ដំណើរការរៀបចំសេចក្តីព្រាងដីកា

បន្ទាប់ពីសម្រេចឱ្យក្រុម ឬអង្គភាពណាមួយរៀបចំសេចក្តីព្រាងដីកា អ្នកទទួលខុសត្រូវនោះ គួរពិនិត្យ ពិចារណា និងអនុវត្តតាមជំហានសំខាន់៧ដូចខាងក្រោម ៖

- ជំហានទី ១ ៖ ការសិក្សាស្រាវជ្រាវ
- ជំហានទី ២ ៖ ការរៀបចំសេចក្តីព្រាងបឋម
- ជំហានទី ៣ ៖ ការពិភាក្សាលើសេចក្តីព្រាងបឋម
- ជំហានទី ៤ ៖ ការព្រមព្រៀងរបស់ក្រុមប្រឹក្សាលើសេចក្តីព្រាងបឋម។

## ដំណាក់កាលទី ១ ៖ ការសិក្សាស្រាវជ្រាវ

ក្នុងការរៀបចំសេចក្តីព្រាងដីកា អ្នកទទួលខុសត្រូវអាចរៀបចំឱ្យមានការសិក្សាជាមុនអំពីក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងបញ្ហា និងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងការសិក្សានេះ អ្នកទទួលខុសត្រូវក្នុងការរៀបចំសេចក្តីព្រាងដីកា អាចស្វែងរកការពិគ្រោះយោបល់ ឬការស្នើសុំឱ្យមានការគាំទ្រផ្នែកបច្ចេកទេស និងធនធាន ឬសេវាទីប្រឹក្សាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ផ្នែកឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ជាពិសេសតំណាងស្ត្រី យុវជន កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច។

## ដំណាក់កាលទី ២ ៖ រៀបចំសេចក្តីព្រាងបឋម

បន្ទាប់ពីទទួលបានព័ត៌មាននានា អ្នកទទួលខុសត្រូវ ត្រូវរៀបចំសេចក្តីព្រាងបឋមដោយផ្អែកតាមទម្រង់គំរូនៃដីកាដែលចេញដោយក្រុមប្រឹក្សា ដូចមានក្នុងឧបសម្ព័ន្ធទី២ ដោយត្រូវបែងចែកជា៤ផ្នែក ដូចខាងក្រោម ៖

- **ផ្នែកក្បាលលិខិត** ផ្នែកនេះបង្ហាញអំពីប្រភពលិខិត ដែលរួមមាន ៖
  - ឈ្មោះប្រទេស "ព្រះរាជាណាចក្រកម្ពុជា"
  - បាវចនា "ជាតិ សាសនា ព្រះមហាក្សត្រ"
  - រដ្ឋបាល
  - លេខ
- **ផ្នែកមូលបទ** ផ្នែកនេះ បង្ហាញអំពី ៖
  - ចំណងជើងដីកា
  - យោង
  - សម្រេច

- **ផ្នែកខ្លឹមសារ** ផ្នែកនេះបង្ហាញអំពីខ្លឹមសារនៃដីកា ដែលរួមមាន ៖
  - ដីកាអាចចែកជាជំពូកទី១ ជំពូកទី២ និងជំពូកបន្តបន្ទាប់។ ជំពូកនីមួយៗត្រូវបែងចែកជាប្រការ។
  - ជាទូទៅជំពូកទី១ អាចមាន ៖
    + ប្រការ១ ចែងអំពីគោលបំណង
    + ប្រការ២ ចែងអំពី គោលដៅ
    + ប្រការ៣ ចែងអំពីវិសាលភាព
    + ប្រការ៤ ចែងអំពីនិយមន័យ និងវាក្យស័ព្ទនានា តាមការចាំបាច់។
  - ជំពូក និងប្រការបន្តបន្ទាប់ទៀត អាចបរិយាយអំពីបទប្បញ្ញត្តិ និងវិធាននានាដែលត្រូវអនុវត្ត។
  - ជំពូកអវសានប្បញ្ញត្តិចែងអំពីការនិរាករណ៍លិខិតបទដ្ឋានគតិយុត្តិ និងបទប្បញ្ញត្តិណាដែលផ្ទុយនឹងដីកានេះ។
  - ចំពោះប្រការបញ្ចប់ត្រូវចែងអំពីការប្រគល់ភារកិច្ចជូន ថ្នាក់ដឹកនាំ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដែលត្រូវទទួលបន្ទុកអនុវត្តដីកានេះ។
- **ផ្នែកបញ្ចប់** ផ្នែកនេះបង្ហាញអំពី ៖
  - ទីកន្លែង កាលបរិច្ឆេទចេញដីកា
  - មុខងារ និងឋានៈ
  - ហត្ថលេខា
  - បោះត្រា
  - ឈ្មោះហត្ថលេខី
  - ចម្លងជូន

**ជំហានទី ៣ ៖ ការពិភាក្សាលើសេចក្ដីព្រាងបឋម**

បន្ទាប់ពីរៀបចំសេចក្ដីព្រាងបឋមនៃដីកាហើយ អ្នកទទួលខុសត្រូវ ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និង ឬគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា មុននឹងដាក់ជូនគណៈអភិបាលពិនិត្យ និងផ្ដល់យោបល់ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាពជាបឋមទៅលើសេចក្ដីព្រាងដីកានេះ។

**ជំហានទី ៤ ៖ ការព្រមព្រៀងរបស់ក្រុមប្រឹក្សាលើសេចក្ដីព្រាងបឋម**

ដើម្បីធានាថាសមាជិកក្រុមប្រឹក្សាទាំងអស់ មានពេលវេលាគ្រប់គ្រាន់សម្រាប់សិក្សាលើសេចក្ដីព្រាងនេះដោយប្រុងប្រយ័ត្ន រដ្ឋបាលត្រូវផ្ញើសេចក្ដីព្រាងបឋមនេះ ដោយភ្ជាប់ជាមួយនូវរបាយការណ៍ស្ដីពីការរៀបចំសេចក្ដីព្រាងបឋម សេចក្ដីថ្លែងហេតុនៃដំណើរការរៀបចំ និងខ្លឹមសារនៃសេចក្ដីព្រាងបឋម និងឯកសារពាក់ព័ន្ធនានា ទៅឱ្យសមាជិកក្រុមប្រឹក្សាទាំងអស់យ៉ាងហោចណាស់ប្រាំ (៥)ថ្ងៃ មុនកិច្ចប្រជុំក្រុមប្រឹក្សា។

បន្ទាប់ពីទទួលបានសេចក្ដីព្រាងបឋមពីគណៈអភិបាល ប្រធានក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ និងឯកភាពលើសេចក្ដីព្រាងបឋម។ ការពិភាក្សាលើសេចក្ដីព្រាងនេះ អាចធ្វើឡើងនៅក្នុងកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ។ នៅក្នុងកិច្ចប្រជុំពិនិត្យសេចក្ដីព្រាងបឋមនេះ ប្រធានក្រុមប្រឹក្សាអាចចាត់តាំងអភិបាលដើម្បីធ្វើបទបង្ហាញអំពីខ្លឹមសារសំខាន់ៗនៃសេចក្ដីព្រាងបឋម មុនពេលក្រុមប្រឹក្សាពិភាក្សា និងឯកភាព។

ក្នុងការពិភាក្សា ក្រុមប្រឹក្សាអាចពិចារណាលើចំណុចមួយចំនួន ដូចខាងក្រោម ៖

- តើខ្លឹមសារសេចក្តីព្រាងបឋមស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានឬទេ?
- តើខ្លឹមសារនៃសេចក្តីព្រាងបឋម បានបង្ហាញពីការរើសអើងចំពោះជន ឬក្រុមណាមួយឬទេ?
- តើខ្លឹមសារនៃសេចក្តីព្រាងបឋម អាចផ្តល់ផលប៉ះពាល់ដូចម្តេចខ្លះដល់ប្រជាពលរដ្ឋជាបុរស និងស្ត្រី និងក្រុមជនងាយរងគ្រោះ?
- តើខ្លឹមសារនៃសេចក្តីព្រាងបឋម អាចអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាបានដែរឬទេ?
- តើខ្លឹមសារសេចក្តីព្រាងបឋម មានអនុភាពប្រតិសកម្មដែរឬទេ?
- តើខ្លឹមសារនៃសេចក្តីព្រាងបឋម មានការយកចិត្តទុកដាក់ពិសេសណាមួយសម្រាប់ជនងាយរងគ្រោះ ដូចជា ជនពិការ ជនជាតិដើមភាគតិច និងជនក្រីក្រដែរឬទេ?
- តើកិច្ចខិតខំប្រឹងប្រែងដែលត្រូវធ្វើឡើង ដោយរដ្ឋបាលដើម្បីអនុវត្តនូវជម្រើសនេះស្របទៅនឹងអត្ថប្រយោជន៍ ដែលទទួលបានដែរឬទេ?
- ... ។ល ។

តាមរយៈកិច្ចប្រជុំពិនិត្យសេចក្តីព្រាងបឋមនេះ ក្រុមប្រឹក្សាអាចទទួលបានលទ្ធផលដូចខាងក្រោម ៖

- ការឯកភាពទាំងស្រុងលើខ្លឹមសារ និងទម្រង់នៃសេចក្តីព្រាងបឋមនេះ ឬ
- ប្រសិនបើ ក្រុមប្រឹក្សាពិនិត្យឃើញថា ខ្លឹមសារនៃសេចក្តីព្រាងបឋមមិនទាន់គ្រប់ជ្រុងជ្រោយ ឬ មិនច្បាស់លាស់ដែលតម្រូវឱ្យមានការកែសម្រួល ក្រុមប្រឹក្សាណែនាំទៅអ្នកទទួលខុសត្រូវឱ្យធ្វើការកែសម្រួលតាមការសម្រេចរបស់ក្រុមប្រឹក្សា មុនពេលយកសេចក្តីព្រាងបឋមនេះដាក់ឱ្យពិគ្រោះយោបល់ និងបិទផ្សាយជាសាធារណៈ។ ក្នុងករណី ក្រុមប្រឹក្សាយល់ឃើញថាខ្លឹមសារនៃសេចក្តីព្រាងបឋមដែលស្នើឱ្យកែតម្រូវនោះ មានលក្ខណៈរសើប ក្រុមប្រឹក្សាអាចតម្រូវឱ្យអ្នកទទួលខុសត្រូវសិក្សាស្រាវជ្រាវ ឬ ពិគ្រោះយោបល់ជាមួយអ្នកជំនាញបន្ថែមទៀតដើម្បីកែសម្រួល និងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាពឡើងវិញ មុនពេលយកសេចក្តីព្រាងបឋមនេះ ទៅពិគ្រោះយោបល់ និងបិទផ្សាយជាសាធារណៈ។

**កំណត់សម្គាល់ ៖** ក្នុងពេលរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សា ឬគណៈអភិបាលអាចលើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហាទាំងនោះជាបញ្ហារសើប ឬមិនច្បាស់លាស់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងឆ្លើយតបវិញ យ៉ាងយូរសាមសិប (៣០) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានសំណើនោះ។

## ២.៣.១.៣. ការពិគ្រោះយោបល់ និងការបិទផ្សាយ សេចក្តីព្រាងដីកា

ការដាក់ចេញដីការបស់ក្រុមប្រឹក្សា អាចមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដើម្បីធានាឱ្យការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ពិសេសជនងាយរងគ្រោះ និងជនភាគតិច ដែលនឹងទទួលផលប៉ះពាល់ពីការសម្រេចទាំងនោះ ក្រុមប្រឹក្សាចាំបាច់ត្រូវបង្កលក្ខណៈងាយស្រួល និងលើកកម្ពស់ឱ្យប្រជាពលរដ្ឋ និងសង្គមស៊ីវិលបានចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តទាំងនោះ តាំងពីដំណាក់កាលដំបូង។

ការពិគ្រោះយោបល់ និងការបិទផ្សាយសេចក្តីព្រាងដីកា គឺជាវិធីសាស្ត្រដែលត្រូវអនុវត្ត ដើម្បីធានាបាននូវការចូលរួមពិនិត្យ និងផ្តល់យោបល់ពីសំណាក់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។ ការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងដីកានេះ គឺជាកិច្ចការសំខាន់ណាស់ ពីព្រោះបន្ទាប់ពីដីកាត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត នោះប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាត្រូវតែអនុវត្តតាមបញ្ញត្តិដែលបានកំណត់។

អាស្រ័យហេតុនេះ បន្ទាប់ពីបានទទួលការឯកភាពពីក្រុមប្រឹក្សាលើសេចក្តីព្រាងបឋមនៃដីកា ប្រធានក្រុមប្រឹក្សាត្រូវណែនាំអ្នកទទួលខុសត្រូវធ្វើការពិគ្រោះយោបល់ និងបិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងដីកានោះ។

ក្នុងការពិគ្រោះយោបល់ និងការបិទផ្សាយសេចក្តីព្រាងដីកា អ្នកទទួលខុសត្រូវអាចពិចារណាអនុវត្តនូវសកម្មភាពដូចខាងក្រោម ៖

- ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ

- ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល
- ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាដទៃទៀត
- ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ននានា
- ការបិទផ្សាយសេចក្តីព្រាងដីកាជាសាធារណៈ
- ការបូកសរុបមតិយោបល់។

## គ. ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ

ក្នុងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អ្នកទទួលខុសត្រូវអាចអនុវត្តនូវវិធីសាស្ត្រមួយចំនួនដូចខាងក្រោម ៖

- **កិច្ចប្រជុំជាសាធារណៈ** ៖ អ្នកទទួលខុសត្រូវអាចរៀបចំកិច្ចប្រជុំជាសាធារណៈជាមួយប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីពិភាក្សា និងប្រមូលមតិយោបល់នានាទៅលើខ្លឹមសារសំខាន់ៗនៃដីកាដែលខ្លួនបានរៀបចំ។ នៅក្នុងកិច្ចប្រជុំនេះ អ្នកទទួលខុសត្រូវអាចធ្វើការបង្ហាញអំពីខ្លឹមសារនៃដីកា និងផ្តល់ឱកាស និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទាំងបុរស ទាំងស្ត្រីដែលបានចូលរួមផ្តល់មតិយោបល់ឱ្យបានផុលផុស។ អ្នកទទួលខុសត្រូវ ត្រូវកត់ត្រានូវរាល់មតិយោបល់ទាំងនោះ ដើម្បីជាមូលដ្ឋានក្នុងការពិចារណាកែសម្រួលសេចក្តីព្រាង។
- **ការពិភាក្សាជាមួយក្រុមគោលដៅជាក់លាក់** ៖ ក្រៅពីកិច្ចប្រជុំជាសាធារណៈជាមួយប្រជាពលរដ្ឋ អ្នកទទួលខុសត្រូវអាចរៀបចំកិច្ចប្រជុំជាមួយក្រុមប្រជាពលរដ្ឋគោលដៅជាក់លាក់នានាផង

ដែរ។ **ឧទាហរណ៍** ៖ ដីកាពាក់ព័ន្ធនឹងការទប់ស្កាត់បទល្មើសនេសាទ អ្នកទទួលខុសត្រូវអាចរៀបចំកិច្ចប្រជុំជាមួយប្រជានេសាទដើម្បីពិគ្រោះយោបល់លើសេចក្តីព្រាងដីកានោះ។

នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំងពីរខាងលើ អ្នកទទួលខុសត្រូវអាចប្រើប្រាស់សំណួរគន្លឹះមួយចំនួនដូចជា ៖

- តើខ្លឹមសារនៃសេចក្តីព្រាងដីកា មានផលប៉ះពាល់អវិជ្ជមានដូចម្តេចខ្លះដល់ប្រជាពលរដ្ឋ?
- តើខ្លឹមសារនៃសេចក្តីព្រាងដីកា អាចអនុវត្តបានដែរឬទេ?
- តើដីកាគួរចូលជាធរមាននៅពេលណា?
- តើប្រជាពលរដ្ឋមានមតិយោបល់កែលម្អបន្ថែមអ្វីខ្លះដល់ខ្លឹមសារនៃសេចក្តីព្រាងដីកា?
- ... ។ល។

## ខ. ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល

អ្នកទទួលខុសត្រូវត្រូវរៀបចំការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលនានា ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការពិគ្រោះយោបល់នេះ អាចធ្វើឡើងតាមរយៈវិធីសាស្ត្រមួយចំនួនដូចខាងក្រោម ៖

- **ការពិភាក្សាជាក្រុម** ៖ អ្នកទទួលខុសត្រូវអាចជ្រើសរើស និងអញ្ជើញតំណាងសង្គមស៊ីវិលពាក់ព័ន្ធនានា ដើម្បីចូលរួមការពិគ្រោះយោបល់ទៅលើសេចក្តីព្រាងដីកាដែលបានរៀបចំ។

  **ឧទាហរណ៍** ៖ ដីកាពាក់ព័ន្ធនឹងការទប់ស្កាត់បទល្មើសនេសាទ អ្នក

ទទួលខុសត្រូវអាចរៀបចំកិច្ចប្រជុំជាមួយសង្គមស៊ីវិល ដែលធ្វើការពាក់ព័ន្ធនឹងវិស័យធនធានធម្មជាតិ និងបរិស្ថានដើម្បីពិគ្រោះយោបល់លើសេចក្តីព្រាងដីកានោះ។

- **ការពិភាក្សាដោយឡែកៗជាមួយសង្គមស៊ីវិល** ៖ ក្រៅពីការពិភាក្សាជាក្រុម អ្នកទទួលខុសត្រូវអាចជួបពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិលនីមួយៗដោយឡែកៗពីគ្នាផងដែរ។
- **ការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ** ៖ អ្នកទទួលខុសត្រូវអាចបញ្ជូនសេចក្តីព្រាងដីកាទៅឱ្យសង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់។ បន្ទាប់ពីទទួលបានសេចក្តីព្រាង សង្គមស៊ីវិលអាចពិនិត្យ និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ និងបញ្ជូនយោបល់នោះមកឱ្យរដ្ឋបាលវិញ។ ដើម្បីធានាថា ការពិនិត្យ និងផ្តល់យោបល់បានទាន់ពេលវេលា អ្នកទទួលខុសត្រូវគួរកំណត់ពេលវេលានៃការបញ្ជូនយោបល់ត្រលប់ឱ្យបានជាក់លាក់។

នៅក្នុងការពិភាក្សា និងប្រមូលមតិយោបល់ទាំងនេះ អ្នកទទួលខុសត្រូវអាចធ្វើការបង្ហាញអំពីខ្លឹមសារនៃដីកា កត់ត្រា និងពិនិត្យមើលនូវរាល់មតិយោបល់ទាំងនោះ ដើម្បីជាមូលដ្ឋានក្នុងការពិចារណាកែសម្រួលសេចក្តីព្រាងដីកា។

### គ. ការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត

ដើម្បីធានាសង្គតិភាព និងមានព័ត៌មានគ្រប់គ្រាន់ក្នុងការកែសម្រួលសេចក្តីព្រាងដីកា ក្រុមប្រឹក្សាត្រូវធានាឱ្យមានការពិគ្រោះយោបល់ជាមួយ

រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដទៃទៀត ដូចជា ៖

- រដ្ឋបាលរាជធានី ត្រូវធ្វើការពិគ្រោះយោបល់ជាមួយ រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់នៅក្នុងរាជធានី
- រដ្ឋបាលខេត្ត ត្រូវធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋបាលស្រុក រដ្ឋបាលក្រុង រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដែលរងផលប៉ះពាល់នៅក្នុងខេត្ត
- រដ្ឋបាលក្រុងត្រូវធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋបាលសង្កាត់នៅក្នុងក្រុង
- រដ្ឋបាលស្រុក ត្រូវធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋបាលឃុំសង្កាត់នៅក្នុងស្រុក
- រដ្ឋបាលខណ្ឌ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋបាលសង្កាត់នៅក្នុងខណ្ឌ។

ជាមួយគ្នានេះ ក្រុមប្រឹក្សាក៏អាចពិគ្រោះយោបល់លើសេចក្តីព្រាងដីការបស់ខ្លួនជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត ដែលមិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់។

ក្នុងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាពាក់ព័ន្ធ ក្រុមប្រឹក្សាអាចពិចារណាវិធីសាស្រ្តមួយចំនួន ដូចខាងក្រោម ៖

- ក្រុមប្រឹក្សាបញ្ជូនសេចក្តីព្រាងដីកានេះទៅក្រុមប្រឹក្សាដទៃទៀត ដើម្បីផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ។ ក្រុមប្រឹក្សាត្រូវកំណត់កាលបរិច្ឆេទ ដើម្បីឱ្យក្រុមប្រឹក្សាទាំងអស់ដឹងអំពីពេល

កំណត់ដែលត្រូវផ្តល់យោបល់ត្រលប់។ កាលបរិច្ឆេទកំណត់នេះគួរមានរយៈពេលសមស្រប ដើម្បីឱ្យក្រុមប្រឹក្សាមានឱកាសគ្រប់គ្រាន់ សម្រាប់ពិភាក្សាលើសេចក្តីព្រាងដីកានេះ។

- ក្រុមប្រឹក្សារាជធានីអញ្ជើញប្រធានក្រុមប្រឹក្សាខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ឱ្យចូលរួមក្នុងការស្តាប់បទបង្ហាញអំពីខ្លឹមសារនៃសេចក្តីព្រាងដីកា។ បន្ទាប់មក ប្រធានក្រុមប្រឹក្សាខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ ត្រូវរៀបចំកិច្ចប្រជុំជាមួយសមាជិកក្រុមប្រឹក្សារបស់ខ្លួន និងអ្នកពាក់ព័ន្ធនានាដើម្បីពិភាក្សាលើសេចក្តីព្រាងដីកានេះ និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយដែលបានកំណត់។
- ក្រុមប្រឹក្សាខេត្តអាចអញ្ជើញប្រធានក្រុមប្រឹក្សាក្រុង និងប្រធានក្រុមប្រឹក្សាស្រុកឱ្យចូលរួមក្នុងការស្តាប់បទបង្ហាញអំពីខ្លឹមសារនៃសេចក្តីព្រាងដីកា។ បន្ទាប់មក ប្រធានក្រុមប្រឹក្សាក្រុង ប្រធានក្រុមប្រឹក្សាស្រុក ត្រូវរៀបចំកិច្ចប្រជុំជាមួយសមាជិកក្រុមប្រឹក្សារបស់ខ្លួន និងអ្នកពាក់ព័ន្ធនានាដើម្បីពិភាក្សាលើសេចក្តីព្រាងដីកានេះ និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយដែលបានកំណត់។ ករណីនេះ ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកអាចពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ។
- ក្រុមប្រឹក្សាក្រុងអាចអញ្ជើញ៖
  - ប្រធានក្រុមប្រឹក្សាសង្កាត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យចូលរួមក្នុងការស្តាប់បទបង្ហាញ អំពីខ្លឹមសារនៃសេចក្តីព្រាង

ដីកា។ បន្ទាប់មកប្រធានក្រុមប្រឹក្សាសង្កាត់ ត្រូវរៀបចំកិច្ច ប្រជុំជាមួយសមាជិកក្រុមប្រឹក្សារបស់ខ្លួន និងអ្នកពាក់ព័ន្ធ នានាដើម្បីពិភាក្សាលើសេចក្តីព្រាងដីកានេះ និងផ្តល់យោបល់ ជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយដែលបានកំណត់ ឬ

- សមាជិកក្រុមប្រឹក្សាសង្កាត់ទាំងអស់ នៅក្នុងដែនសមត្ថកិច្ច របស់ខ្លួនឱ្យចូលរួមស្តាប់បទបង្ហាញ និងពិភាក្សាអំពីខ្លឹមសារ នៃសេចក្តីព្រាងដីកាតែម្តង។

• ក្រុមប្រឹក្សាស្រុកអាចអញ្ជើញ ៖

- មេឃុំ និងចៅសង្កាត់ទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចូលរួមក្នុងការស្តាប់បទបង្ហាញអំពីខ្លឹមសារនៃសេចក្តីព្រាង ដីកា។ បន្ទាប់មក ក្រុមប្រឹក្សាឃុំសង្កាត់ ធ្វើការពិភាក្សាពី សេចក្តីព្រាងដីកានេះ និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមួយ ដែលបានកំណត់ ឬ
- សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់ឱ្យមកចូលរួមក្នុងការ ស្តាប់បទបង្ហាញ និងពិភាក្សាអំពីខ្លឹមសារនៃសេចក្តីព្រាង ដីកាតែម្តង។

### ឃ. ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ននានា

ក្នុងករណីដែលក្រុមប្រឹក្សា និងឬគណៈអភិបាលយល់ឃើញថា បញ្ហា ឬបញ្ញត្តិដែលចែងក្នុងដីកាមានលក្ខណៈរសើប ឬមិនច្បាស់លាស់ ក្រុមប្រឹក្សា ឬ គណៈអភិបាលអាចស្នើសុំទៅក្រសួងមហាផ្ទៃ ឬក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បី

ឱ្យក្រសួង ស្ថាប័នទាំងនោះពិនិត្យ និងផ្តល់យោបល់ មុនពេលក្រុមប្រឹក្សាពិនិត្យ និងអនុម័តដាក់ឱ្យអនុវត្តនូវដីកាណាមួយនោះ។

លើសពីនេះ ក្នុងករណីដែលខ្លឹមសារនៃសេចក្តីព្រាងដីកាពាក់ព័ន្ធនឹងការអនុវត្តមុខងារដែលបានផ្ទេរ (តាមរយៈប្រតិភូកម្ម ឬប្រគល់) ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សា និងឬគណៈអភិបាលក៏អាចស្នើសុំមតិយោបល់ពីអ្នកជំនាញដែលមកពីក្រសួង ស្ថាប័នពាក់ព័ន្ធនោះតាមការចាំបាច់ផងដែរ។

**ឧទាហរណ៍** ៖ ក្រុមប្រឹក្សាស្រុកមួយមានគម្រោងដាក់ចេញដីកាសម្រាប់គ្រប់គ្រងព្រៃសហគមន៍នៅក្នុងស្រុករបស់ខ្លួន។ បន្ទាប់ពីបានរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សាបានពិគ្រោះយោបល់លើសេចក្តីព្រាងដីកាជាមួយអ្នកជំនាញមកពីខណ្ឌ ឬសង្កាត់រដ្ឋបាលព្រៃឈើជាដើម។

## ខ. ការបិទផ្សាយសេចក្តីព្រាងដីកាជាសាធារណៈមុនធ្វើសេចក្តីសម្រេច

ដើម្បីឱ្យប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាមានឱកាសចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងដីកា ក្រុមប្រឹក្សាត្រូវចាត់ឱ្យរដ្ឋបាលរបស់ខ្លួនធ្វើការបិទផ្សព្វផ្សាយជាសាធារណៈ មុនពេលក្រុមប្រឹក្សាធ្វើការពិភាក្សាចុងក្រោយ និងអនុម័ត។ ក្នុងការបិទផ្សាយជាសាធារណៈនេះ គណៈអភិបាលត្រូវធានា ៖

- ផ្សព្វផ្សាយសេចក្តីព្រាងដីកា និងរបៀបនៃការផ្តល់យោបល់នៅតាមក្តារព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ និងនៅទីសាធារណៈផ្សេងៗទៀត ព្រមទាំងតាមរយៈវិទ្យុ ឬទូរទស្សន៍ ឬឧបករណ៍បំពងសំឡេងនានា ដើម្បីឱ្យប្រជា

ពលរដ្ឋ និងសង្គមស៊ីវិលចូលរួមផ្តល់យោបល់លើសេចក្តីព្រាងដីកា ដោយបញ្ជាក់ពីទីកន្លែង និងពេលវេលានៃការទទួលយកមតិយោបល់។

- មានទីកន្លែង មន្ត្រី បុគ្គលិក និងប្រអប់សំបុត្រ សម្រាប់ទទួលមតិយោបល់នានា។

ការបិទផ្សាយសេចក្តីព្រាងដីកាជាសាធារណៈ ត្រូវទុកពេលយ៉ាងតិចដប់ថ្ងៃ (១០) នៃថ្ងៃធ្វើការ មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត លើកលែងករណីចាំបាច់ និងបន្ទាន់ក្នុងការដាក់ចេញនូវដីកានេះ។

**ច. ការបូកសរុបមតិយោបល់**

បន្ទាប់ពីការពិគ្រោះយោបល់ និងការបិទផ្សាយសេចក្តីព្រាងដីកាជាសាធារណៈ អ្នកទទួលខុសត្រូវ ត្រូវ ៖

- បូកសរុបមតិយោបល់នានាដែលបានលើកឡើង
- ពិនិត្យ និងពិចារណាមតិយោបល់ដែលបានលើកឡើង
- ពិនិត្យ និងកែសម្រួលសេចក្តីព្រាងដីកាដោយផ្អែកលើមតិយោបល់ដែលបានលើកឡើង
- រៀបចំ និងបញ្ចប់សេចក្តីព្រាងដីកា និងដាក់ជូនគណៈអភិបាលផ្តល់យោបល់ មុនពេលដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

បន្ទាប់ពីបូកសរុបមតិយោបល់រួច អ្នករៀបចំត្រូវដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ មុនពេលដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

## ២.៣.១.៤. ការពិនិត្យ និងការអនុម័តដីកា

### ក. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាល

បន្ទាប់ពីទទួលបានសេចក្តីព្រាងចុងក្រោយពីអ្នករៀបចំ គណៈអភិបាលត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងដីកា។ អ្នករៀបចំ ត្រូវធ្វើការកែសម្រួលសេចក្តីព្រាងដីកាតាមការអនុសាសន៍របស់គណៈអភិបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

នៅក្នុងការបញ្ជូនសេចក្តីព្រាងដីកាចុងក្រោយទៅក្រុមប្រឹក្សា អភិបាលត្រូវភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីការរៀបចំសេចក្តីព្រាងដីកា សេចក្តីថ្លែងហេតុ ព្រមទាំងមតិយោបល់នានាដែលបានប្រមូលពីការពិគ្រោះយោបល់ និងបិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងដីកាចុងក្រោយឱ្យបានប្រាំ (៥)ថ្ងៃ មុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

### ខ. ការពិនិត្យ និងអនុម័តរបស់ក្រុមប្រឹក្សា

ក្រោយពេលទទួលបាននូវសេចក្តីព្រាងដីកា ប្រធានក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងដីកានោះ។ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវធានាឱ្យមានការចូលរួមពីគណៈអភិបាល មន្ទីរ អង្គភាព និងអ្នកជំនាញដែលពាក់ព័ន្ធ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

ដំណើរការនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងដីកា ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

នៅក្នុងការពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងដីកា ក្រុមប្រឹក្សាត្រូវ

ចាត់ឱ្យអភិបាលរាយការណ៍ និងបង្ហាញជូនក្រុមប្រឹក្សាអំពីដំណើរការ និងខ្លឹមសារសំខាន់ៗនៃសេចក្ដីព្រាងដីកា ព្រមទាំងមតិយោបល់នានាដែលទទួលបានពីការពិគ្រោះយោបល់ និងបិទផ្សាយជាសាធារណៈ ដើម្បីឱ្យក្រុមប្រឹក្សាមានមូលដ្ឋានក្នុងការពិចារណា និងវាយតម្លៃផលប៉ះពាល់ដែលអាចមានមុនពេលអនុម័ត។

បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័តលើសេចក្ដីព្រាងដីកា អភិបាលត្រូវរៀបចំកែសម្រួលបញ្ចប់សេចក្ដីព្រាងដីកា និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា ឬត្រូវបំពេញភារកិច្ចផ្សេងទៀតផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា។

ប្រសិនបើសេចក្ដីព្រាងនេះទទួលបានមតិយោបល់អវិជ្ជមានច្រើននោះក្រុមប្រឹក្សាគួរណែនាំគណៈអភិបាល ៖

- ធ្វើការសិក្សាស្រាវជ្រាវ និងពិភាក្សាជាមួយអ្នកជំនាញ និងអ្នកពាក់ព័ន្ធនានាបន្ថែមទៀត ដើម្បីកែសម្រួលផ្នែកខ្លះនៃសេចក្ដីព្រាងដីកាឡើងវិញ។
- រៀបចំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល ក្រុមប្រឹក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងអ្នកពាក់ពន្ធ័បន្ថែមទៀត។
- បូកសរុបនូវមតិយោបល់ អនុសាសន៍អំពីការពិគ្រោះយោបល់នេះដើម្បីកែសម្រួលសេចក្ដីព្រាងដីកា មុនដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងសម្រេចម្ដងទៀត។

# គំនូសបំព្រួញស្ដីពី
# ដំណើរការរៀបចំដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ



### ២.៣.២. ដីកាមានលក្ខណៈជាឯកត្តភូត

ដីកាដែលមានលក្ខណៈជាឯកត្តភូត សំដៅលើដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទាក់ទងនឹងការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចរបស់មន្ត្រីរាជការស៊ីវិលក្នុងមុខដំណែង ស្របតាមអនុក្រឹត្យលេខ៤៩៧អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣។

អភិបាលរាជធានី ខេត្តទទួលបានប្រតិភូកម្មសិទ្ធិអំណាចក្នុងការចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ជំហានសំខាន់៧សម្រាប់ការរៀបចំតាក់តែងដីកាដែលមានលក្ខណៈឯកត្តភូត រួមមាន ៖

- ការលើកសំណើអំពីការតែងតាំង ការផ្លាស់ប្តូរ ឬបញ្ចប់
- ការរៀបចំតាក់តែងសេចក្តីព្រាងដីកា
- ការពិនិត្យផ្តល់យោបល់របស់គណៈអភិបាល
- ការពិនិត្យ និងអនុម័តរបស់ក្រុមប្រឹក្សា
- ការចុះហត្ថលេខាលើដីកា។

#### ២.៣.២.១. ការលើកសំណើអំពីតម្រូវការដីកា

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែង ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងការលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្ត

តាមបែបបទ និងនីតិវិធីដូចបានកំណត់ក្នុងសេចក្តីណែនាំលេខ២២០២ស.ណ.ន ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤ ចេញដោយក្រសួងមុខងារសាធារណៈ ។

### ២.៣.២.២. ការរៀបចំតាក់តែងសេចក្តីព្រាងដីកា

រាល់ការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងត្រូវដាក់ចេញជាទម្រង់ដីកាដែលមានលក្ខណៈជាឯកត្តភូត ។

ដោយផ្អែកទៅលើតម្រូវការ និងមូលហេតុដែលនាំឱ្យមានការលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែង ព្រមទាំងមានការឯកភាពក្នុងគណៈអភិបាលរបស់ខ្លួន អភិបាលរាជធានី ខេត្តត្រូវចាត់ឱ្យទីចាត់ការគ្រប់គ្រងធនធានមនុស្ស ដើម្បីរៀបចំតាក់តែងសេចក្តីព្រាងដីកាស្តីពីការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការដែលបានស្នើសុំនោះ (ទម្រង់ដីកាមានលក្ខណៈឯកត្តភូតមានក្នុងឧបសម្ព័ន្ធទី៣) ។

### ២.៣.២.៣. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាល

បន្ទាប់ពីបញ្ចប់សេចក្តីព្រាងដីកាបឋម ទីចាត់ការគ្រប់គ្រងធនធានមនុស្សត្រូវដាក់សេចក្តីព្រាងដីកាជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ ។ អភិបាលត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដើម្បីពិនិត្យ ផ្តល់យោបល់លើសេចក្តីព្រាងដីកា ។ ទីចាត់ការគ្រប់គ្រងធនធានមនុស្សត្រូវធ្វើការកែសម្រួលសេចក្តីព្រាងដីកាតាមអនុសាសន៍ណែនាំរបស់គណៈអភិបាល ។

### ២.៣.២.៤. ការពិនិត្យ និងអនុម័តរបស់ក្រុមប្រឹក្សារាជធានី ខេត្ត

បន្ទាប់ពីពិនិត្យ និងកែសម្រួលសេចក្តីព្រាងហើយ អភិបាលរាជធានីខេត្តត្រូវដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តរបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តលើ

សំណើការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់រាជធានី ខេត្ត ។

(សូមមើលខ្លឹមសារលម្អិតក្នុងអនុក្រឹត្យលេខ ៤៩៧ និងសេចក្តីណែនាំលេខ២២០២)

| |
|---|
| **កំណត់សម្គាល់៖** ចំពោះដីកាស្តីពីការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រុង ស្រុក ខណ្ឌ មិនដាក់ឆ្លងការពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្តឡើយ ។ |

### ២.៣.២.៥. ការចុះហត្ថលេខា

- ចំពោះដីកាស្តីពីការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់រាជធានី ខេត្ត បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលរាជធានី ខេត្តត្រូវចុះហត្ថលេខាលើដីកាដែលទទួលបានការអនុម័តនោះ ។
- ចំពោះដីកាស្តីពីការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រុង ស្រុក ខណ្ឌ បន្ទាប់ពិនិត្យ និងកែសម្រួលក្នុងកិច្ចប្រជុំគណៈអភិបាល អភិបាលរាជធានី ខេត្តត្រូវចុះហត្ថលេខាលើដីកាដែលទទួលបានការអនុម័តនោះ ។

## គំនូសបំព្រួញស្តីពី
## ដំណើរការរៀបចំដីកាដែលមានលក្ខណៈឯកត្តភូត



## ២.៤. ការពិនិត្យនីត្យានុកូលភាព

### ក. ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ

រដ្ឋបាលរាជធានី ខេត្តត្រូវបញ្ជូននូវរាល់ដីកាដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួនទៅក្រសួងមហាផ្ទៃយ៉ាងយូរប្រាំ (០៥)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញដីកា ដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

អភិបាលរាជធានី ខេត្តត្រូវបានទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការពិនិត្យនីត្យានុកូលភាពលើដីកាដែលអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក និងខណ្ឌ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបញ្ជូននូវរាល់ដីកាដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួនទៅអភិបាលរាជធានី ខេត្តសាមីយ៉ាងយូរប្រាំ (០៥)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញដីកាដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

ក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តត្រូវសហការជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានាក្នុងការពិនិត្យនីត្យានុកូលភាពលើដីការបស់ក្រុមប្រឹក្សា។

ក្នុងករណីពិនិត្យឃើញថា ដីកាណាមួយមានអនីត្យានុកូលភាព ក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាដែលចេញដីកានោះ ដោយបញ្ជាក់អំពីហេតុផល ឬចំណុចដែលផ្ទុយពីបទបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីឱ្យក្រុមប្រឹក្សាធ្វើការកែតម្រូវឡើងវិញ។

ក្រោយពេលទទួលបានសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តសាមី ក្រុមប្រឹក្សាដែលចេញដីកាត្រូវកែតម្រូវដីកានោះឡើងវិញ

ក្នុងអំឡុងពេលសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងការកែតម្រូវនេះ ក្រុមប្រឹក្សាត្រូវអនុវត្តតាមនីតិវិធីស្ដីពីការរៀបចំ និងការអនុម័តដីកាដូចមានចែងក្នុងអនុក្រឹត្យស្ដីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ឬដូចចំណុចទី២.៣នៃឯកសារបច្ចេកទេសនេះ។

ក្នុងករណីដែលក្រុមប្រឹក្សាណាមួយ មិនបានធ្វើការកែតម្រូវតាមការជូនដំណឹងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្ត រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្ត ត្រូវចាត់វិធានការចាំបាច់នានាដើម្បីឱ្យមានការកែតម្រូវ ឬលុបចោលដីកានោះ។

**ឧទាហរណ៍** ៖ ក្រុមប្រឹក្សាក្រុងបានដាក់ចេញដីកាស្ដីពីការគ្រប់គ្រងបឹងធម្មជាតិក្នុងក្រុង។ បន្ទាប់ពីអនុម័ត អភិបាលក្រុងបានបញ្ជូនដីកានេះ មកអភិបាលខេត្តដើម្បីពិនិត្យនីត្យានុកូលភាព។ បន្ទាប់ពីទទួលបានដីកាពីអភិបាលក្រុង អភិបាលខេត្ត ចាត់ចែងការពិនិត្យនីត្យានុកូលភាពដោយពិចារណានូវចំណុចមួយចំនួនដូចខាងក្រោម ៖

- តើខ្លឹមសារនៃដីកាស្របជាមួយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែរឬទេ?
- តើខ្លឹមសារនៃដីកានេះស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាសាមីដែរឬទេ?

ក្នុងករណីអភិបាលខេត្តពិនិត្យឃើញថា បញ្ញត្តិណាមួយ ឬចំនួននៃដីកានេះមិនស្របតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដែលបានកំណត់ អភិបាលខេត្តត្រូវជូនដំណឹងទៅរដ្ឋបាលក្រុងនោះដើម្បីធ្វើការកែតម្រូវ។

## ខ. ដីកាដែលមានលក្ខណៈឯកត្តភូត

ចំពោះដីកាដែលមានលក្ខណៈឯកត្តភូត បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីនោះក្នុងរយៈពេលយ៉ាងយូរ០៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការទៅក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យនីត្យានុកូលភាព និងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបចំបៀវត្ស និងការងារក្របខ័ណ្ឌ។

**កំណត់សម្គាល់ ៖**

- បន្ទាប់ពីដីកាចូលជាធរមាន គណៈអភិបាលអាចចាត់ចែងអនុវត្តដីការបស់ក្រុមប្រឹក្សាខ្លួន ទោះបីជាមិនទាន់បានការពិនិត្យនីត្យានុកូលភាពក៏ដោយ ។
- ក្នុងករណីពិនិត្យឃើញថា ប្រការមួយចំនួននៃដីកានោះពុំស្របច្បាប់ រដ្ឋបាលដែលមានតួនាទីពិនិត្យនីត្យានុកូលភាពត្រូវបង្ហាញហេតុផលឱ្យបានច្បាស់លាស់ និងប្រការដែលមិនស្របច្បាប់ ព្រមទាំងត្រូវផ្តល់ការណែនាំ ឬអនុសាសន៍សម្រាប់កែតម្រូវ ។
- ក្រុមប្រឹក្សាត្រូវធ្វើការកែតម្រូវតាមការណែនាំរបស់រដ្ឋបាលដែលពិនិត្យនីត្យានុកូលភាពនោះ ។
- ក្នុងករណីក្រុមប្រឹក្សាណាមួយមិនធ្វើការកែតម្រូវដីកាតាមការជូនដំណឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្ត នឹងចាត់វិធានការដើម្បីឱ្យមានការកែតម្រូវ ឬលុបចោលដីកានោះ ។

# ផ្នែកទី៣
# ការអនុវត្ត ការកែប្រែ និង
# ការលុបចោលដីកា

# ផ្នែកទី៣
# ការអនុវត្ត ការកែប្រែ និងការលុបចោលដីកា

## ៣.១. ការអនុវត្តដីកា

ដីកាដែលអាចអនុវត្តបាន លុះត្រាតែដីកានោះបានចូលជាធរមាន។ ដីកាអាចចូលជាធរមាននៅថ្ងៃដែលដីកានោះត្រូវបានចុះហត្ថលេខា ឬអាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគត សម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬផ្នែកខ្លះនៃដីកា។

ក្រុមប្រឹក្សាត្រូវធានាថា រាល់ដីកាដែលបានអនុម័តរួចត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន និងអ្នកពាក់ព័ន្ធនានា។ ក្នុងការផ្សព្វផ្សាយនេះ គណៈអភិបាលគួរពិចារណាចំណុចសំខាន់ៗ ដូចខាងក្រោម ៖

- សង្ខេបពីខ្លឹមសារ និងវិធានសំខាន់ៗដែលមានចែងនៅក្នុងដីកានេះ ដើម្បីបិទផ្សាយលើក្តារព័ត៌មានរបស់ក្រុមប្រឹក្សាពាក់ព័ន្ធនានា ដែលស្ថិតនៅក្រោមវិសាលភាពនៃដីកានេះ។
- បញ្ជូនដីកា និងសេចក្តីសង្ខេបអំពីខ្លឹមសារ និងវិធានសំខាន់ៗនៅក្នុងដីកានេះទៅកាន់ស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងសារព័ត៌មាន ដោយស្នើឱ្យស្ថានីយ៍ទាំងនេះជួយធ្វើការផ្សព្វផ្សាយ។
- ស្នើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ផ្សព្វផ្សាយដីកា តាមរយៈក្តារព័ត៌មាន ឬឧបករណ៍បំពងសំឡេង ឬតាមទីសាធារណៈនានា។
- ស្នើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគេហទំព័រធ្វើការផ្សព្វផ្សាយដីកា និងសេចក្តីសង្ខេបអំពីខ្លឹមសារដីកាលើគេហទំព័រនោះ។

- ណែនាំឱ្យរដ្ឋបាលរៀបចំខិតប័ណ្ណ ដែលមានដកស្រង់ខ្លឹមសារ និង វិធានសំខាន់ៗពីដីកានេះ ហើយត្រូវចែកខិតប័ណ្ណនេះដល់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ។

| |
|---|
| **កំណត់សម្គាល់** ៖ ក្រុមប្រឹក្សា ត្រូវចាត់ឱ្យមានមន្ត្រីទទួលបន្ទុកក្នុងការបកស្រាយរាល់ចម្ងល់របស់ប្រជាពលរដ្ឋលើខ្លឹមសារនៃដីកាដែលបានផ្សព្វផ្សាយ។ ក្រុមប្រឹក្សាត្រូវធានាថា ជនងាយរងគ្រោះ ជនពិការ ស្ត្រី និង យុវជនបានទទួលព័ត៌មានអំពីដីកានេះ។ |

ការអនុវត្តដីកា ត្រូវធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាទាំងមូល លើកលែងតែដីកាចែងផ្សេងពីនេះ ឬ លើកលែងតែច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តជាធរមានណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលមានការកំណត់ដែនសមត្ថកិច្ចច្បាស់លាស់។

គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ក្រុមប្រឹក្សា ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងត្រូវធ្វើរបាយការណ៍ជាប្រចាំ ឬតាមការកំណត់របស់ក្រុមប្រឹក្សា។ ក្នុងការចាត់ចែងអនុវត្តដីកានេះ គណៈអភិបាលត្រូវធានាឱ្យមានការចូលរួមពីមន្ទីរ អង្គភាពជំនាញ សាធារណជន និងអ្នកពាក់ព័ន្ធនានា។ គណៈអភិបាល គួររៀបចំផែនការអនុវត្តដីកាឱ្យបានច្បាស់លាស់ ដោយបញ្ចូលនូវសកម្មភាពបណ្តុះបណ្តាលផ្សព្វផ្សាយដល់អ្នកដែលនឹងចូលរួមអនុវត្តដីកានេះផងដែរ។

ក្នុងករណីចាំបាច់ គណៈអភិបាលអាចពង្រឹងការអនុវត្តដីកាតាមរយៈ

ឬដោយមានកិច្ចសហការជាមួយនគរបាលយុត្តិធម៌។ នគរបាលយុត្តិធម៌ត្រូវជួយក្រុមប្រឹក្សា ដើម្បីពង្រឹងការអនុវត្តដីការបស់ក្រុមប្រឹក្សានៅពេលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីគណៈអភិបាល។

ក្រុមប្រឹក្សាត្រូវធានាឱ្យមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តដីការបស់ខ្លួន ដូចជា៖

- របាយការណ៍របស់គណៈអភិបាល
- របាយការណ៍សំខាន់ៗដទៃទៀត
- សាកសួរគណៈអភិបាល ឬ នាយករដ្ឋបាល
- ការត្រួតពិនិត្យផ្ទាល់ដល់មូលដ្ឋាន ក្នុងករណីចាំបាច់ ដើម្បីធានាថា ដីកាត្រូវបានអនុវត្តត្រឹមត្រូវ
- មធ្យោបាយផ្សេងៗទៀត។

## ៣.២. ការកែប្រែ និងការលុបចោលដីកា

ក្រុមប្រឹក្សាអាចសម្រេចកែប្រែ ឬលុបចោលដីកាណាមួយដែលខ្លួនបានអនុម័តរួច ដោយផ្អែកតាមស្ថានភាព បញ្ហា តម្រូវការ ឬ សំណូមពរពីមូលដ្ឋាន និងឬដោយផ្អែកតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ឬតាមការណែនាំពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

ការកែប្រែដីកាអាចធ្វើឡើងដោយបន្ថែមប្រការថ្មី និងឬ កែប្រែប្រការណាមួយនៃដីកាដែលមានស្រាប់។ ការកែប្រែដីកាត្រូវអនុវត្តតាមនីតិវិធីស្តីពីការរៀបចំ និងការអនុម័តដីកា ដូចមានចែងក្នុងឯកសារបច្ចេកទេសនេះ។

ក្រុមប្រឹក្សាអាចសម្រេចកែប្រែ ឬ លុបចោលដីកាណាមួយតាមរយៈការចេញដីការបស់ខ្លួន។

**ឧទាហរណ៍ ៖** បន្ទាប់ពីដាក់ចេញដីកាស្តីពីការគ្រប់គ្រងបឹងធម្មជាតិក្នុងស្រុក ក្រុមប្រឹក្សាស្រុកបានពិនិត្យឃើញថា ប្រការដែលចែងក្នុងដីកានេះមិនទាន់គ្រប់គ្រាន់ ពាក់ព័ន្ធទៅនឹងការហាមឃាត់ការធ្វើស្រែក្នុងផ្ទៃបឹងនៅរដូវប្រាំង។ ដូច្នេះ ក្រុមប្រឹក្សាសម្រេចកែសម្រួលដីកានេះ ដោយបន្ថែមប្រការថ្មីពាក់ព័ន្ធទៅនឹងការហាមឃាត់ការធ្វើស្រែក្នុងផ្ទៃបឹងនៅរដូវប្រាំង តាមរយៈការចេញដីកាស្តីពីការកែសម្រួលដីកាស្តីពីការគ្រប់គ្រងបឹងធម្មជាតិ។

## ៣.៣. ការដាក់ពិន័យ

ដោយសារតែដីកាមានលក្ខណៈចងកាតព្វកិច្ចតាមផ្លូវច្បាប់ សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដីកាក៏អាចមានដាក់បញ្ចូលនូវការដាក់ពិន័យសម្រាប់ករណីដែលមានអ្នកមិនគោរពតាមបទបញ្ជាទាំងនេះផងដែរ។ ការដាក់ពិន័យទាំងនេះត្រូវអនុវត្តដូចៗគ្នា សម្រាប់ប្រជាពលរដ្ឋទាំងអស់ ដោយមិនគិតពីឋានៈរបស់ពួកគេក្នុងសង្គម យេនឌ័រ ឬសាវតារនោះឡើយ។

បែបបទ និងនីតិវិធីនៃការរៀបចំបទប្បញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ដោយដីការបស់ក្រុមប្រឹក្សា និងកម្រិតនៃប្រាក់ពិន័យនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# ឧបសម្ព័ន្ធទី១ ៖ អនុក្រឹត្យលេខ ២៨៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៨៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## នីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ។

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងជានាការប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការរៀបចំ ការកែប្រែ និងការលុបចោលដីកាដែល មានលក្ខណៈជាបទបញ្ជាទូទៅរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តនៅរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **ដីកា** គឺជាវិធានខាងផ្លូវច្បាប់ មានលក្ខណៈជាបទបញ្ជាទូទៅ ឬមានលក្ខណៈជាឯកត្តភូត ដែល អនុម័តដោយក្រុមប្រឹក្សាក្នុងព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួន សម្រាប់អនុវត្តក្នុងដែនសមត្ថកិច្ច របស់ខ្លួន។ ដីកាអាចជាដីកាដើម ឬដីកាដែលកែប្រែដីកាដើម ឬដីកាដែលកែប្រែដីកាមួយផ្សេង ទៀត ឬដីកាដែលលុបចោលដីកាមួយផ្សេងទៀត។
- **ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ** គឺជាការណែនាំការអនុវត្ត ឬបញ្ជាក់បន្ថែមខ្លឹមសារ របស់ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស និងជាការណែនាំការអនុវត្តកិច្ចការដែលស្ថិត នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ ត្រូវអនុម័ត ដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា។
- **ដីកាដែលមានលក្ខណៈជាឯកត្តភូត** គឺជាដីកាដែលទាក់ទង ឬសំដៅចំឈ្មោះបុគ្គល។ ដីកា ដែលមានលក្ខណៈជាឯកត្តភូតត្រូវអនុម័តដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយអភិបាល។
- **ដីកាដើម** សំដៅដល់ដីកាដំបូងដែលបានរៀបចំ និងអនុម័តដោយក្រុមប្រឹក្សា។

- **ដែនសមត្ថកិច្ច** គឺជាតំបន់ ជាមុខងារ និងជាភារកិច្ច ដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា។
- **ប្រតិសកម្ម** សំដៅដល់អានុភាពអនុវត្តត្រឡប់ក្រោយចំពោះស្ថានភាព ឬករណីទាំងឡាយណាដែលបានកើតមានឡើងមុនដីកាចូលជាធរមាន។
- **ការពិនិត្យនីត្យានុកូលភាព** គឺជាការត្រួតពិនិត្យ ដើម្បីធានាថា ដីការបស់ក្រុមប្រឹក្សាត្រូវបានរៀបចំឡើងស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។
- **នគរបាលយុត្តិធម៌** សំដៅដល់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។ នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

## ជំពូកទី២

## គោលការណ៍សំខាន់ៗនៃការដាក់ចេញដីកា

**មាត្រា ៥.-**

ដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ ត្រូវអនុម័តដោយក្រុមប្រឹក្សា និងត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា។

**មាត្រា ៦.-**

ដីកាដែលចែងផ្ទុយពីបទបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដីកានោះនឹងមិនមានសុពលភាពបានឡើយ។

**មាត្រា ៧.-**

ដីកាណាមួយដែលធ្វើឡើងដោយមានការរើសអើង ក្នុងន័យជាអវិជ្ជមាន ឬអនុវត្តចំពោះបុគ្គលណាម្នាក់ ឬក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ជំនឿ ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬជាតិកំណើត ឬអសមត្ថភាពខាងស្មារតីឬខាងកាយសម្បទា ដីកានោះនឹងមិនមានសុពលភាពបានឡើយ។

**មាត្រា ៨.-**

ក្រុមប្រឹក្សា ត្រូវធានាឱ្យមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំដីកា លើកលែងតែក្នុងករណីចាំបាច់ដែលតម្រូវឱ្យក្រុមប្រឹក្សាត្រូវដាក់ចេញនូវដីកាដើម្បីដោះស្រាយ ឬចាត់វិធានការបន្ទាន់ណាមួយ។

**មាត្រា ៩.-**

ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលដីកានោះត្រូវបានចុះហត្ថលេខា ឬអាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគតសម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬផ្នែកខ្លះនៃដីកា។

**មាត្រា ១០.-**

ដីកាមិនអាចមានអានុភាពប្រតិសកម្មបានឡើយ។

## ជំពូកទី៣

## សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការចេញដីកា

**មាត្រា ១១.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការដាក់ចេញដីកា ការកែប្រែ និងការលុបចោលដីកាស្របតាមនីតិវិធី ដែលមានចែងនៅក្នុងបទបញ្ញត្តិនានានៃអនុក្រឹត្យនេះ។

**មាត្រា ១២.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌមានសិទ្ធិដាក់ចេញដីកា ដើម្បីកំណត់ ដើម្បីហាមឃាត់ ឬដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬលើកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនធានរបស់ខ្លួនរួមមាន ៖

- តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា
- មុខងារ និងឬធនធានដែលប្រគល់ទៅឱ្យក្រុមប្រឹក្សា
- មុខងារ និងឬធនធានដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះមិនកំណត់ដោយផ្នែកខ្លះ ឬទាំងស្រុងនូវសិទ្ធិក្នុងការអនុម័តដីកា និង
- កិច្ចការណាមួយដែលច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដែលតម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា។

**មាត្រា ១៣.-**

ដីកាអាចដាក់បញ្ចូលនូវបទបញ្ញត្តិស្តីពីការពិន័យជាប្រាក់ ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌនិងការទទួលខុសត្រូវរដ្ឋប្បវេណីផ្សេងៗទៀតចំពោះការបំពានលើបទបញ្ញត្តិមួយ ឬច្រើនដែលមានចែងនៅក្នុងដីកា។

**មាត្រា ១៤.-**

បែបបទ និងនីតិវិធីនៃការរៀបចំបទបញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ដោយដីការបស់ក្រុមប្រឹក្សា និងកម្រិតនៃប្រាក់ពិន័យនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## ការរៀបចំ និងការអនុម័តដីកា

### ផ្នែកទី១

### ការកំណត់អំពីតម្រូវការនៃការដាក់ចេញដីកា

**មាត្រា ១៥.-**

តម្រូវការនៃការដាក់ចេញដីកា ត្រូវបានកំណត់ដោយផ្អែកតាមតម្រូវការនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងឬតម្រូវការក្នុងមូលដ្ឋាន។

ការផ្តួចផ្តើមអំពីតម្រូវការនៃការដាក់ចេញដីកាដោយផ្អែកតាមតម្រូវការក្នុងមូលដ្ឋាន អាចស្នើឡើងដោយ ៖

- ប្រធានក្រុមប្រឹក្សា ឬ
- សមាជិកក្រុមប្រឹក្សាមួយភាគបី( ១/៣ )នៃសមាជិកក្រុមប្រឹក្សាទាំងមូល ឬ
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ឬ
- អភិបាល ឬគណៈអភិបាល ឬ
- សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចនីមួយៗ ឬ
- តំណាងគ្រួសារចំនួនមួយភាគដប់( ១/១០ )នៃចំនួនគ្រួសារសរុបដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

**មាត្រា ១៦.-**

តម្រូវការនៃការដាក់ចេញដីកាត្រូវអនុម័តដោយក្រុមប្រឹក្សា។

## ផ្នែកទី២

## ការរៀបចំសេចក្តីព្រាងដីកា

**មាត្រា ១៧.-**

ការរៀបចំសេចក្តីព្រាងដីកាត្រូវផ្អែកតាមគោលការណ៍ ឬវិធាននានានៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និង ឬតម្រូវការនៅមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ក្នុងការរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សាអាចរៀបចំឱ្យមានការសិក្សាជាមុនអំពីក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បញ្ហា និងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងការសិក្សានេះ ក្រុមប្រឹក្សាអាចស្វែងរកការពិគ្រោះយោបល់ ឬការស្នើសុំឱ្យមានការគាំទ្រផ្នែកបច្ចេកទេស និងធនធាន ឬសេវាទីប្រឹក្សាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ផ្នែកឯកជន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ១៨.-**

ក្នុងការរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សាអាចប្រគល់ភារកិច្ចឱ្យ ៖

- សមាជិកក្រុមប្រឹក្សា ឬ
- គណៈអភិបាល ឬ
- គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សា ឬ
- អង្គភាពណាមួយរបស់ក្រុមប្រឹក្សា។

សេចក្តីព្រាងដីកា ត្រូវរៀបចំឡើងដោយផ្អែកតាមទម្រង់ដីកាដែលកំណត់ដោយសេចក្តីណែនាំ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សាត្រូវជានាឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ជាពិសេសតំណាងស្ត្រី យុវជន កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច ក្នុងការរៀបចំសេចក្តីព្រាងដីកា។

**មាត្រា ២០.-**

ក្នុងពេលរៀបចំសេចក្តីព្រាងដីកា ក្រុមប្រឹក្សា ឬគណៈអភិបាលអាចលើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហាទាំងនោះជាបញ្ហារសើប ឬមិនច្បាស់លាស់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវឆ្លើយតបវិញយ៉ាងយូរសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើនោះ។

## ផ្នែកទី៣

## ការពិគ្រោះយោបល់ និងការបិទផ្សាយសេចក្តីព្រាងដីកាជាសាធារណៈ

**មាត្រា ២១.-**

រាល់សេចក្តីព្រាងដីកា ត្រូវមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ និងឬគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា មុននឹងដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាពជាបឋមទៅលើសេចក្តីព្រាងដីកានេះ។

**មាត្រា ២២.-**

សេចក្តីព្រាងដីកាដែលបានការឯកភាពជាបឋមពីក្រុមប្រឹក្សា ត្រូវមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ សាធារណជន និងអ្នកពាក់ព័ន្ធដទៃទៀត និងត្រូវជូនដំណឹងនិងបិទផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនៅក្នុងរដ្ឋបាលរបស់ខ្លួន និងនៅទីសាធារណៈ ដើម្បីឱ្យសាធារណជន និងអ្នកពាក់ព័ន្ធនានាបានទទួលព័ត៌មានអំពីខ្លឹមសារនៃសេចក្តីព្រាងដីកា និងមានឱកាសផ្តល់យោបល់។

ការជូនដំណឹង និងការបិទផ្សាយជាសាធារណៈនេះ ត្រូវមានរយៈពេលយ៉ាងតិចដប់(១០)ថ្ងៃនៃថ្ងៃធ្វើការ មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត លើកលែងតែករណីចាំបាច់ និងបន្ទាន់ក្នុងការដាក់ចេញនូវដីកានោះដូចមានចែងក្នុងមាត្រា៨នៃអនុក្រឹត្យនេះ។

**មាត្រា ២៣.-**

ក្រុមប្រឹក្សាត្រូវធានាឱ្យមានយន្តការច្បាស់លាស់ ក្នុងការទទួលយកព័ត៌មានត្រឡប់ពីសាធារណជន និងអ្នកពាក់ព័ន្ធនានាអំពីសេចក្តីព្រាងដីកា ដោយរៀបចំឱ្យមានទីកន្លែង មធ្យោបាយ មន្ត្រីទទួលបន្ទុកសម្រាប់ទទួលយកយោបល់ត្រឡប់ពីសាធារណជន និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ២៤.-**

អភិបាលត្រូវធានាថា រាល់យោបល់ដែលទទួលបានពីការពិគ្រោះយោបល់ និងការបិទផ្សាយជាសាធារណៈ ត្រូវបានយកមកពិចារណាក្នុងការកែសម្រួលសេចក្តីព្រាងដីកា និងត្រូវធានាឲ្យមានការរៀបចំរបាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ និងការបិទផ្សាយជាសាធារណៈនេះ ដើម្បីភ្ជាប់ជាមួយនឹងសេចក្តីព្រាងដីកាដែលបានកែសម្រួលសម្រាប់ដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

## ផ្នែកទី៤
## ការពិនិត្យ និងការអនុម័តដីកា

**មាត្រា ២៥.-**

សេចក្តីព្រាងដីកាដែលបានកែសម្រួលរួច ត្រូវដាក់ជូនគណៈអភិបាលពិនិត្យ និងរៀបចំដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ដោយភ្ជាប់មកជាមួយនូវបាយការណ៍ស្តីពីលទ្ធផលនៃការពិគ្រោះយោបល់ និងការបិទផ្សាយជាសាធារណៈ និងសេចក្តីថ្លែងហេតុស្តីពីកិច្ចដំណើរការរៀបចំ និងខ្លឹមសារនៃសេចក្តីព្រាងដីកា។

**មាត្រា ២៦.-**

ក្រោយពេលទទួលបាននូវសេចក្តីព្រាងដីកា ប្រធានក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងដីកានោះ។

ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវជានាឲ្យមានការចូលរួមពីគណៈអភិបាល មន្ទីរ អង្គភាព និងអ្នកជំនាញដែលពាក់ព័ន្ធ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់សាធារណជន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

**មាត្រា ២៧.-**

ដំណើរការនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងដីកា ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

ក្រុមប្រឹក្សាត្រូវអនុម័តសេចក្តីព្រាងដីកា ដោយសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។

**មាត្រា ២៨.-**

បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័តលើសេចក្តីព្រាងដីកា អភិបាលត្រូវរៀបចំកែសម្រួល និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា ឬត្រូវបំពេញភារកិច្ចផ្សេងទៀតផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា។

## ជំពូកទី៥
## ការកែប្រែ និងការលុបចោលដីកា

**មាត្រា ២៩.-**

ក្រុមប្រឹក្សាអាចសម្រេចកែប្រែ ឬលុបចោលដីកាណាមួយដែលខ្លួនបានអនុម័តរួច ដោយផ្អែកតាមស្ថានភាព បញ្ហា តម្រូវការ ឬសំណូមពរពីមូលដ្ឋាន និង ឬដោយផ្អែកតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ឬតាមការណែនាំពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

**មាត្រា ៣០.-**

ការកែប្រែដីកាអាចធ្វើឡើងដោយបន្ថែមប្រការថ្មី និងឬកែប្រែប្រការណាមួយនៃដីកាដែលមានស្រាប់។

ការកែប្រែដីកាត្រូវអនុវត្តតាមនីតិវិធីស្តីពីការរៀបចំ និងការអនុម័តដីកា ដូចមានចែងក្នុងជំពូកទី៤ នៃអនុក្រឹត្យនេះ។

**មាត្រា ៣១.-**

ក្រុមប្រឹក្សាអាចសម្រេចលុបចោលដីកាណាមួយតាមរយៈដីការបស់ខ្លួន។

# ជំពូកទី៦
## ការអនុវត្តដីកា

**មាត្រា ៣២.-**

ដីកាដែលអាចអនុវត្តបាន លុះត្រាតែដីកានោះបានចូលជាធរមាន ដូចដែលមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សាត្រូវធានាថា រាល់ដីកាដែលបានអនុម័តរួច ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ៣៣.-**

ការអនុវត្តដីកាត្រូវធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាទាំងមូល លើកលែងតែដីកាចែងផ្សេងពីនេះ ឬលើកលែងតែច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន គតិយុត្តជាធរមានណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលមានការកំណត់ដែនសមត្ថកិច្ចច្បាស់លាស់។

**មាត្រា ៣៤.-**

ក្រុមប្រឹក្សាត្រូវអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ខ្លួន។

គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ក្រុមប្រឹក្សា ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងត្រូវធ្វើរបាយការណ៍ជាប្រចាំ ឬតាមការកំណត់របស់ក្រុមប្រឹក្សា។ ក្នុងការចាត់ចែងអនុវត្តដីកានេះ គណៈអភិបាលត្រូវធានាឱ្យមានការចូលរួមពីមន្ទីរ អង្គភាពជំនាញ សាធារណជន និងអ្នកពាក់ព័ន្ធនានា។

ក្នុងករណីចាំបាច់ គណៈអភិបាលអាចពង្រឹងការអនុវត្តដីកាតាមរយៈ ឬដោយមានកិច្ចសហការជាមួយនគរបាលយុត្តិធម៌។

នគរបាលយុត្តិធម៌ត្រូវជួយក្រុមប្រឹក្សា ដើម្បីពង្រឹងការអនុវត្តដីការបស់ក្រុមប្រឹក្សានៅពេលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីគណៈអភិបាល។

**មាត្រា ៣៥.-**

ក្រុមប្រឹក្សាត្រូវធានាឱ្យមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តដីការបស់ខ្លួន។

# ជំពូកទី៧
## ការពិនិត្យនីត្យានុកូលភាពនៃដីកា

**មាត្រា ៣៦.-**

រដ្ឋបាលរាជធានី ខេត្តត្រូវបញ្ជូននូវរាល់ដីកាដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួនទៅក្រសួងមហាផ្ទៃយ៉ាងយូរប្រាំ(០៥)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញដីកា ដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

អភិបាលរាជធានី ខេត្តត្រូវបានទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការពិនិត្យនីត្យានុកូលភាពលើដីកាដែលអនុម័តដោយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបញ្ជូននូវរាល់ដីកាដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន ទៅអភិបាលរាជធានី ខេត្តសាមីយ៉ាងយូរប្រាំ(០៥)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញដីកាដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

**មាត្រា ៣៧.-**

ក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តត្រូវសហការជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនានាក្នុងការពិនិត្យនីត្យានុកូលភាពលើដីការបស់ក្រុមប្រឹក្សា។

**មាត្រា ៣៨.-**

ក្នុងករណីពិនិត្យឃើញថា ដីកាណាមួយមានអនីត្យានុកូលភាព ក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាដែលចេញដីកានោះ ដោយបញ្ជាក់អំពីហេតុផល ឬចំណុចដែលផ្ទុយពីបទបញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដើម្បីឱ្យក្រុមប្រឹក្សាធ្វើការកែតម្រូវឡើងវិញ។

ក្រោយពេលទទួលបានសេចក្ដីជូនដំណឹងពីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តសាមី ក្រុមប្រឹក្សាដែលចេញដីកាត្រូវកែតម្រូវដីកានោះឡើងវិញក្នុងអំឡុងពេលសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងការកែតម្រូវនេះ ក្រុមប្រឹក្សាត្រូវអនុវត្តតាមនីតិវិធីស្ដីពីការរៀបចំ និងការអនុម័តដីកាដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ។

ក្នុងករណីដែលក្រុមប្រឹក្សាណាមួយ មិនបានធ្វើការកែតម្រូវតាមការជូនដំណឹងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្ត រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលរាជធានី ខេត្តត្រូវចាត់វិធានការចាំបាច់នានាដើម្បីឱ្យមានការកែតម្រូវ ឬលុបចោលដីកានោះ។

## ជំពូកទី៨
## បទបញ្ញត្តិដោយឡែក

**មាត្រា ៣៩.-**

ដីកាដែលមានលក្ខណៈជាឯកត្តភូត ត្រូវចុះហត្ថលេខាដោយអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សា។

កិច្ចដំណើរការនៃការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តភូត ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ត្រីបុគ្គលិក ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៩
## អន្តរបញ្ញត្តិ

**មាត្រា ៤០.-**

រាល់ដីកាដែលក្រុមប្រឹក្សា ឬអភិបាលបានដាក់ចេញមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវនៅមានសុពលភាពរហូតដល់ដីកាទាំងនោះតម្រូវឲ្យមានការកែប្រែ ឬការរៀបចំជាថ្មី។

ការកែប្រែ ឬការរៀបចំជាថ្មីនូវដីកាទាំងនោះ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិនានានៃអនុក្រឹត្យនេះ។

## ជំពូកទី១០

## អវសានបញ្ញត្តិ

**មាត្រា ៤១.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

**ស ខេង**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៤២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី២ ៖
# ទម្រង់ដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ

**ទម្រង់គំរូដីកាដែលមានលក្ខណៈជាបទបញ្ជាទូទៅ**

**ក្បាលលិខិត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ៖ ......................
រដ្ឋបាលក្រុង ស្រុក ខណ្ឌ ៖ ...............
លេខ ៖ ......................

**ដីកា**

**ស្តីពី....................................**

**ក្រុមប្រឹក្សាស្រុក..............................**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ.... ចុះថ្ងៃទី.... ខែ..... ឆ្នាំ..... ស្តីពីការបង្កើតរដ្ឋបាលរាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌ..... (បើមាន)
- យោងតាមស្មារតីនៃកិច្ចប្រជុំ............. លើកទី........ របស់ក្រុមប្រឹក្សា....... នាថ្ងៃទី...... ខែ....... ឆ្នាំ......

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

ប្រការ ១.- (អាចកំណត់អំពីគោលបំណងនៃដីកា)

ប្រការ ២.- (អាចកំណត់អំពីគោលដៅនៃដីកា)

ប្រការ ៣.- (អាចកំណត់អំពីវិសាលភាពនៃដីកា)

ប្រការ ៤.- (អាចកំណត់អំពីវាក្យស័ព្ទសំខាន់ៗដែលមានក្នុងដីកា "បើមាន")

## ជំពូកទី២
## ................ (ខ្លឹមសារ ឬបញ្ញត្តិនានា) ..............

ប្រការ.....-

ប្រការ.....-

ប្រការ.....-

## ជំពូកទី...

.......................

ប្រការ.....-

ប្រការ.....-

## ជំពូកទី...
## អវសានប្បញ្ញត្តិ

ប្រការ.....- (អាចកំណត់អំពីការនិរាករណ៍)

ប្រការ.....- (អាចកំណត់អំពីអ្នកទទួលបន្ទុកអនុវត្តដីកា)

ធ្វើនៅ............... ថ្ងៃទី........... ខែ............... ឆ្នាំ...........

**ជ.ក្រុមប្រឹក្សា..............**

**ប្រធាន**

**កន្លែងទទួល ៖**

- ក្រសួងមហាផ្ទៃ (សម្រាប់ដីការាជធានី ខេត្ត)
- រដ្ឋបាលរាជធានី ខេត្ត...
- រដ្ឋបាលឃុំ សង្កាត់
- ដូចប្រការ... (ប្រការដែលកំណត់អំពីអ្នកទទួលបន្ទុកអនុវត្ត)
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣ ៖ ទម្រង់ដីកាដែលមានលក្ខណៈឯកត្តភូត

**ទម្រង់គំរូនៃដីកាដែលមានលក្ខណៈឯកត្តភូត**
**( ក្បាលលិខិត )**

រាជធានី ខេត្ត ៖ ....................
លេខ ៖ ....................

**ដីកា**
**ស្តីពី**
**ការតែងតាំង ឬប្រគល់ភារកិច្ចជូនមន្ត្រីរាជការ**

---

**អភិបាល នៃគណៈអភិបាល**......................

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ (សម្រាប់រដ្ឋបាលរាជធានី ខណ្ឌ)
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក (សម្រាប់រដ្ឋបាលខេត្ត ក្រុង ស្រុក)
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល (សម្រាប់ដីកាស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យក្របខ័ណ្ឌ និងឋានន្តរស័ក្តិ )
- បានឃើញអនុក្រឹត្យលេខ ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- យោងសេចក្តីណែនាំលេខ ២២០២ មស.សណន ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រសួងមុខងារ

សាធារណៈ ស្តីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

- លិខិតលេខ.......ចុះថ្ងៃទី.....ខែ....ឆ្នាំ......របស់ក្រសួងមហាផ្ទៃស្តីពី..........(ខ្លឹមសារលិខិតដែលបានផ្តល់ការឯកភាពលើសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចនាយកទីចាត់ការហិរញ្ញវត្ថុ) ( ករណីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចនាយកទីចាត់ការហិរញ្ញវត្ថុ)
- បានទទួលការអនុម័តពីក្រុមប្រឹក្សារាជធានីភ្នំពេញ ក្នុងកិច្ចប្រជុំលើកទី.... (ប្រជុំសាមញ្ញ) ឬវិសាមញ្ញ នាថ្ងៃទី ......ខែ.........ឆ្នាំ២០........

**សម្រេច**

**ប្រការ ១ .-**

ត្រូវបានតែងតាំងលោក លោកស្រី..............អត្តលេខ..... (បើមាន) ឋានន្តរស័ក្តិ.........ថ្នាក់លេខ............ នៃក្របខ័ណ្ឌ..........ជា..........(មុខតំណែង)......... (ឈ្មោះអង្គភាព ឬការិយាល័យនៃសាលា...............)។ ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន.......រូប នៅ......... (ការិយាល័យ ឬអង្គភាពនៃសាលា................)...... ដូចមានរាយនាមខាងក្រោម ៖ (**ករណីតែងតាំង ឬមន្ត្រីច្រើនរូប** )

១. លោក................អត្តលេខ.....(បើមាន) ឋានន្តរស័ក្តិ.........ថ្នាក់លេខ........នៃក្របខ័ណ្ឌ.........
ជា............................. (ឈ្មោះ អង្គភាព ឬការិយាល័យ) ។

២. លោក................អត្តលេខ.....(បើមាន)ឋានន្តរស័ក្តិ.........ថ្នាក់លេខ........នៃក្របខ័ណ្ឌ.........
ជា.............................(ឈ្មោះ អង្គភាព ឬការិយាល័យ ) ។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីកានេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ .-**

នាយក នាយករងរដ្ឋបាលសាលា............... ប្រធានការិយាល័យ អង្គភាពជំនាញ ប្រធានអង្គភាព ប្រធានការិយាល័យចំណុះរចនាសម្ព័ន្ធសាលារាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌ ឬមេឃុំ ចៅសង្កាត់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តដីកានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ............ ថ្ងៃទី ខែ ឆ្នាំ២០.....

**អភិបាលរាជធានី ខេត្ត**

***កន្លែងទទួល*** ÷

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត...
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ...
- រដ្ឋបាលឃុំ សង្កាត់ ...

<u>"ដើម្បីជ្រាប"</u>

- ដូចប្រការ១ និង៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

**ទម្រង់គំរូនៃដីកាដែលមានលក្ខណៈឯកត្តតូត**

**( ក្បាលលិខិត )**

រាជធានី ខេត្ត ៖ ....................

លេខ ៖ ....................

**ដីកា**

**ស្តីពី**

**ការផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ**

**អភិបាល នៃគណៈអភិបាល**................

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ (សម្រាប់រដ្ឋបាលរាជធានី ខណ្ឌ)
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក (សម្រាប់រដ្ឋបាលខេត្ត ក្រុង ស្រុក)
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល (សម្រាប់ដីកាស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យក្របខ័ណ្ឌ និងឋានន្តរស័ក្តិ )
- បានឃើញអនុក្រឹត្យលេខ ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ... 

សាធារណៈ ស្ដីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្ដូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

- លិខិតលេខ.......ចុះថ្ងៃទី.....ខែ....ឆ្នាំ......របស់ក្រសួងមហាផ្ទៃស្ដីពី..........(ខ្លឹមសារលិខិតដែលបានផ្ដល់ការឯកភាពលើសំណើតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចនាយកទីចាត់ការហិរញ្ញវត្ថុ) ( ករណីតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចនាយកទីចាត់ការហិរញ្ញវត្ថុ)
- បានទទួលការអនុម័តពីក្រុមប្រឹក្សារាជធានីភ្នំពេញ ក្នុងកិច្ចប្រជុំលើកទី.... (ប្រជុំសាមញ្ញ) ឬវិសាមញ្ញ នាថ្ងៃទី ......ខែ.........ឆ្នាំ២០........

## សម្រេច

**ប្រការ ១ .-**

ត្រូវបានផ្លាស់ប្ដូរភារកិច្ចលោក.............អត្តលេខ.....(បើមាន)ឋានន្តរស័ក្តិ.........ថ្នាក់លេខ........នៃក្របខ័ណ្ឌ. ............ពី.....(មុខតំណែងបច្ចុប្បន្ន)......ឱ្យទៅបម្រើការងារជា........(មុខតំណែងថ្មី)............ ។ ឬ

ត្រូវបានផ្លាស់ប្ដូរភារកិច្ចមន្ត្រីរាជការចំនួន...........រូបនៅ............. (ការិយាល័យឬអង្គភាពនៃសាលា..........) ដូចមានរាយនាមខាងក្រោម៖ (ករណីមន្ត្រីច្រើនរូប)

១. លោក................អត្តលេខ........(បើមាន)ឋានន្តរស័ក្តិ..................ថ្នាក់លេខ.........នៃក្របខ័ណ្ឌ........ពី(មុខតំណែងបច្ចុប្បន្ន).........ឱ្យទៅបម្រើការងារជា............(មុខតំណែងថ្មី)....... ។

២. លោក................អត្តលេខ........(បើមាន)ឋានន្តរស័ក្តិ..................ថ្នាក់លេខ.........នៃក្របខ័ណ្ឌ........ពី (មុខតំណែងបច្ចុប្បន្ន).......ឱ្យទៅបម្រើការងារជា..............(មុខតំណែងថ្មី)...... ។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីកានេះត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

នាយក នាយករងរដ្ឋបាលសាលា............... ប្រធានការិយាល័យ អង្គភាពជំនាញ ប្រធានអង្គភាព ប្រធានការិយាល័យចំណុះរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តដីកានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ............ ថ្ងៃទី ខែ ឆ្នាំ២០.....

**អភិបាលរាជធានី ខេត្ត**

**<u>កន្លែងទទួល</u>** ÷

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត...
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ...
- រដ្ឋបាលឃុំ សង្កាត់ ...

"ដើម្បីជ្រាប"

- ដូចប្រការ១ និងប្រការ ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

## ទម្រង់គំរូនៃដីកាដែលមានលក្ខណៈឯកត្តភូត
## ( ក្បាលលិខិត )

រាជធានី ខេត្ត ៖ ....................

លេខ ៖ ....................

# ដីកា
# ស្តីពី
# ការបញ្ចប់ភារកិច្ចមន្ត្រីរាជការ

### អភិបាល នៃគណៈអភិបាល........................

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ (សម្រាប់រដ្ឋបាលរាជធានី ខណ្ឌ)
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក (សម្រាប់រដ្ឋបាលខេត្ត ក្រុង ស្រុក)
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តន៍វិន័យចំពោះមន្ត្រីរាជការស៊ីវិល (សម្រាប់ដីកាស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ដែលទទួលទណ្ឌកម្មវិន័យនាំឱ្យបញ្ចប់ភារកិច្ចសាមីខ្លួន )
- បានឃើញអនុក្រឹត្យលេខ ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- យោងសេចក្តីណែនាំលេខ ២២០២ មស.សណន ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រសួងមុខងារ

សាធារណៈ ស្តីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

- លិខិតលេខ.......ចុះថ្ងៃទី.....ខែ....ឆ្នាំ......របស់ក្រសួងមហាផ្ទៃស្តីពី..........(ខ្លឹមសារលិខិតដែលបានផ្តល់ការឯកភាពលើសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចនាយកទីចាត់ការហិរញ្ញវត្ថុ) (ករណីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចនាយកទីចាត់ការហិរញ្ញវត្ថុ)
- បានទទួលការអនុម័តពីក្រុមប្រឹក្សារាជធានីភ្នំពេញ ក្នុងកិច្ចប្រជុំលើកទី.... (ប្រជុំសាមញ្ញ) ឬវិសាមញ្ញ នាថ្ងៃទី ......ខែ.........ឆ្នាំ២០........

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបញ្ចប់ភារកិច្ចលោក...........អត្តលេខ.....(បើមាន)ឋានន្តរស័ក្តិ.........ថ្នាក់លេខ........នៃក្របខ័ណ្ឌ......
...ពី (មុខតំណែងបច្ចុប្បន្ន)...................................... ។ ឬ

ត្រូវបានបញ្ចប់ភារកិច្ចមន្ត្រីរាជការចំនួន.......រូប នៅ....... (ការិយាល័យ ឬអង្គភាព).......ដូចមានរាយនាមខាងក្រោម ៖( ករណីមន្ត្រីច្រើនរូប )

១. លោក......................អត្តលេខ........(បើមាន)ឋានន្តរស័ក្តិ............ថ្នាក់លេខ..........នៃក្របខ័ណ្ឌ.........ពី( មុខតំណែងបច្ចុប្បន្ន)........................................ ។

២. លោក......................អត្តលេខ........(បើមាន)ឋានន្តរស័ក្តិ............ថ្នាក់លេខ..........នៃក្របខ័ណ្ឌ.........ពី( មុខតំណែងបច្ចុប្បន្ន)........................................ ។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីកានេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ .-**

នាយក នាយករងរដ្ឋបាលសាលា............... ប្រធានការិយាល័យ អង្គភាពជំនាញ ប្រធានអង្គភាព ប្រធានការិយាល័យចំណុះរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តដីកានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ............ ថ្ងៃទី ខែ ឆ្នាំ២០.....

**អភិបាលរាជធានី ខេត្ត**

**កន្លែងទទួល** ÷
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត...
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ...
- រដ្ឋបាលឃុំ សង្កាត់ ...

"ដើម្បីជ្រាប"

- ដូចប្រការ១ និង ប្រការ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ